## កូនសៀវភៅណែនាំ

### ការវាយតម្លៃផលប៉ះពាល់នៃច្បាប់

### Regulatory Impact Assessment (RIA)

# វិធីសាស្ត្រសិក្សា វិភាគ និងវាយតម្លៃផលប៉ះពាល់នៃច្បាប់


ដឹកនាំស្រាវជ្រាវ និងកែសម្រួលដោយៈ **ឯកឧត្តម អ៊ី សារិទ្ធ**
**អគ្គលេខាធិការព្រឹទ្ធសភា**

ស្រាវជ្រាវ និងចងក្រងដោយៈ **លោក គឹម សុចិត្រា**
**លោក គុន គុន្ធូ**
**លោក សាន ចាន់ណាក់**
**លោក សំអឿន ម៉ារឌី**



**ខែ កុម្ភៈ ឆ្នាំ ២០១១**

# ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

# មាតិកា


ទំព័រ

| | |
|---|---|
| អារម្ភកថា | i |
| សេចក្តីផ្តើម | ១ |
| ១-ការកំណត់បញ្ហា Identify Problem | ៧ |
| ២-ការកំណត់គោលបំណង Define Objective | ១១ |
| ៣-ការកំណត់ជម្រើសដំណោះស្រាយ Identify Options | ១៣ |
| ៤-ការវិភាគលើផលប៉ះពាល់ធៀប និងថ្លៃត្រូវចំណាយនៃជម្រើសនិមួយៗImpact(cost/benefits)Analysis | ១៧ |
| ៥-ការប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធ Consulting the Stakeholders | ២៥ |
| ៦-ការធ្វើសេចក្តីសន្និដ្ឋាននិងការកំនត់ជម្រើសសមស្របបំផុត Choose Recommended Option | ២៨ |
| ៧-ដំណាក់កាលអនុវត្ត និងត្រួតពិនិត្យការអនុវត្ត Implementation and Review | ៣៣ |
| -សេចក្តីសន្និដ្ឋាន | ៣៤ |
| -ករណីសិក្សា | ៣៨ |
| -មេរៀនសង្ខេប «ការវាយតម្លៃផលប៉ះពាល់នៃច្បាប់» | ៤៨ |
| -ឯកសារពិគ្រោះ | ៥៦ |

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានបញ្ចប់ការវាយតម្លៃរយៈពេល១០ឆ្នាំនៃកិច្ចដំណើរការ (១៩៩៩-២០០៩) របស់ខ្លួនប្រកបដោយជោគជ័យ ។ ជាលទ្ធផលនៃការវាយតម្លៃនេះ យើងបានរកឃើញនូវចំនុចខ្សោយមួយចំនួនដែលបញ្ជាក់ថា សមត្ថភាពមន្ត្រីរាជការមួយចំនួន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាយើង មានត្រឹមតែផ្នែករដ្ឋបាល និងបច្ចេកទេសប៉ុណ្ណោះ។ចំណែកឯសមត្ថភាពឯកទេសក្នុងការវិភាគ និងផ្តល់យោបល់តាមវិស័យ ជូនគណៈកម្មការជំនាញ និងសមាជិកាសមាជិកព្រឹទ្ធសភា នៅមានកម្រិតទាបនៅឡើយ ។ នេះមានន័យថា សមត្ថភាពប្រមូលព័ត៌មាន ទិន្នន័យ ដើម្បីវិភាគ សំយោគ និងវាយតម្លៃនៅមានកំរិត ។

ដោយមើលឃើញនូវសារសំខាន់ និងមានបំណងចង់បង្កើនសមត្ថភាពមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាពិសេសបំពេញនូវចំនុចខ្វះខាតខាងលើ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តួចផ្តើមស្រាវជ្រាវ និងចងក្រងនូវកូនសៀវភៅ

ណែនាំស្តីពី « វិធីសាស្ត្រសិក្សា វិភាគ និងវាយតម្លៃផលប៉ះពាល់នៃច្បាប់/បទប្បញ្ញត្តិ » នេះឡើង ដើម្បីជាទុនសម្រាប់ការសិក្សា និងវិភាគប្រកបដោយលក្ខណៈត្រឹមត្រូវ និងមិនលំអៀងលើអត្ថបទច្បាប់ និងបទប្បញ្ញត្តិនានា ដែលត្រូវដាក់ចេញ ឬលើការកែប្រែនៃច្បាប់ និងបទប្បញ្ញត្តិនានា ដែលមានស្រាប់ ហើយមានបញ្ជាក់ពីអំណះអំណាងច្បាស់លាស់អំពីតម្លៃត្រូវចំណាយ និងផលប្រយោជន៍ដែលទទួលបានទាំងបែបគុណភាព (Qualitative Analysis) និងបរិមាណ (Quantitative Analysis)។

ឯកសារនេះគឺបានប្រមូលបញ្ចូលគ្នាទាំងផ្នែកទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែង ព្រោះមានករណីសិក្សាឆ្លុះបញ្ចាំងនូវបញ្ហាច្បាស់លាស់ ដែលកើតមានឡើងរួចមកហើយ និងត្រូវបានដោះស្រាយដោយប្រើតាមបច្ចេកទេសការវាយតម្លៃផលប៉ះពាល់នៃច្បាប់ (Regulatory Impact Assessment-RIA) របស់ប្រទេសឥណ្ឌូនេស៊ី។

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា មន្ត្រីរាជការនៃអគ្គលេ-ធិការដ្ឋានព្រឹទ្ធសភាទាំងអស់ នឹងប្រើប្រាស់នូវចំណេះដឹងថ្មីតាមរយៈកូនសៀវភៅនេះ ដើម្បីជាប្រយោជន៍ក្នុងការពង្រឹងការអនុវត្តមុខងាររបស់ខ្លួនក្នុងការផ្តល់សេវាឯកទេស ជូន

គណៈកម្មការជំនាញ សមាជិកា សមាជិកព្រឹទ្ធសភាលើមុខងារនីតិកម្ម និងមុខងារព័ត៌មានឲ្យកាន់តែមានប្រសិទ្ធភាព ឆ្ពោះទៅកាន់វឌ្ឍនភាពរបស់ស្ថាប័ននាពេលអនាគត ។

ខ្ញុំសូមថ្លែងនូវការកោតសរសើរ ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃនាយកដ្ឋានស្រាវជ្រាវទូទៅ ដែលបានផ្តួចផ្តើមគំនិតស្រាវជ្រាវចងក្រង និងបង្កើតឲ្យមាននូវឯកសារដ៏មានសារសំខាន់នេះឡើង ប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ ។ និងសូមសំដែងអំណរគុណជាពន្លឹកចំពោះមូលនិធិអាស៊ី ដែលបានចូលរួមឧបត្ថម្ភ និងគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងរយៈកាលកន្លងមក ពិសេសគឺការរៀបចំឲ្យមានវគ្គបណ្តុះបណ្តាលស្តីពី «ការសិក្សាវិភាគ និងវាយតម្លៃផលប៉ះពាល់នៃច្បាប់» ដែលផ្តល់ជាមូលដ្ឋានគ្រឹះ ក្នុងការកសាងកូនសៀវភៅណែនាំនេះ ។

ភ្នំពេញ ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ ២០១១

**អគ្គលេខាធិការ**

**អ៊ុំ សារឹទ្ធ**

# សេចក្តីផ្តើម

ក្នុងកិច្ចខិតខំប្រឹងប្រែងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងលើកកំពស់សុខមាលភាពសង្គម ការកសាងក្របខណ្ឌច្បាប់ពិតជាមានសារសំខាន់ណាស់ ដូច្នេះការធ្វើឲ្យប្រសើរឡើងនូវគុណភាពផ្នែកច្បាប់រឹតតែមានសារសំខាន់ទៅទៀត។

ច្បាប់ ឬបទប្បញ្ញត្តិនីមួយៗដែលផលិតចេញ អាចនឹងផ្តល់នូវ«ផលល្អ»និង«ផលមិនល្អ»។ ច្បាប់ឬបទប្បញ្ញត្តិ អាចជំរុញលើកកម្ពស់វិស័យសេដ្ឋកិច្ច និងសុខមាលភាពសង្គម ហើយនៅពេលជាមួយគ្នានោះ ក៏អាចនាំមកនូវបន្ទុកចំណាយ (Costs)ផ្នែកសេដ្ឋកិច្ច និងសង្គមផងដែរ។ «**ការវាយតម្លៃផលប៉ះពាល់នៃច្បាប់ឬបទប្បញ្ញត្តិ** (Regulatory Impact Assessment -RIA)» ត្រូវបានគេប្រើប្រាស់ជាឧបករណ៍សារវន្តមួយសម្រាប់ដំណើរការកំណែទម្រង់នានា និងពង្រឹងគុណភាពច្បាប់ឬបទប្បញ្ញត្តិ និងថែមទាំងអាចកាត់បន្ថយនូវការបង្កើតច្បាប់ ឬបទប្បញ្ញត្តិដែលពុំចាំបាច់ និងគ្មានគុណភាពទៀតផង។ RIA ជាឧបករណ៍ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ នៅតាមបណ្តាប្រទេសជាសមាជិក OECD[1] ហើយបាននិងកំពុងតែរីក

---

[1] OECD (Organization for Cooperation and Development): ជាអង្គការដើម្បី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍដែលកកើតឡើងតាមរយៈអនុសញ្ញា ឆ្នាំ ១៩៦០ និងចុះហត្ថលេខាដោយប្រទេសសមាជិកចំនួន២០ហើយរហូតមកដល់

សាយភាយទៅដល់បណ្តាប្រទេសមួយចំនួនរួមទាំងនៅតំបន់អាស៊ីផងដែរ មានជាអាទិ៍ប្រទេសជប៉ុន បង់ក្លាដែស និងឥណ្ឌូនេស៊ី។ល។

កូនសៀវភៅណែនាំអំពី «វិធីសាស្ត្រសិក្សាវិភាគ និងវាយតម្លៃផលប៉ះពាល់នៃច្បាប់» នេះនឹងលើកយកនូវទ្រឹស្តីដែលជាវិធីសាស្ត្រ សិក្សា វិភាគ និងវាយតម្លៃផលប៉ះពាល់នៃច្បាប់ឬបទប្បញ្ញត្តិ ព្រមទាំងឧទាហរណ៍ជាក់ស្តែង របស់ឥណ្ឌូនេស៊ី[2] មកបង្ហាញ។

នៅពេលដែលមានការសម្រេចចិត្តណាមួយថានឹងត្រូវបង្កើតច្បាប់ឬបទប្បញ្ញត្តិថ្មី ឬធ្វើការកែប្រែណាមួយលើច្បាប់ឬបទប្បញ្ញត្តិដែលមានស្រាប់ សំដៅដោះស្រាយ*បញ្ហាណាមួយដែលបានកើតឡើង ឬមានសក្តានុពលនឹងកើតឡើង*[3] គេប្រើ RIA ជាឧបករណ៍ដើម្បី៖

ពេលបច្ចុប្បន្នមានប្រទេសសមាជិកសរុបចំនួន៣៤ (ព័ត៌មានលំអិតបន្ថែមអាច រកបាននូវគេហទំព័រ: www.oecd.org) ។

[2] ឯកសារណែនាំនេះ ប្រើប្រាស់ឯកសារ និងទ្រឹស្តីតាមលំនាំ RIA របស់ឥណ្ឌូនេស៊ី (បណ្ឌិត Hari Setianto អ្នកជំនាញផ្នែក វាយតម្លៃផលប៉ះពាល់នៃច្បាប់)

[3] បញ្ហាដែលបានកើតឡើង ឬមានសក្តានុពលនឹងកើតឡើង: នឹងមានពន្យល់ ពិស្តារក្នុងផ្នែកស្តីពី -**ការកំណត់បញ្ហា**- ខាងក្រោយ ។

(១)-ពិនិត្យពិច័យជាប្រព័ន្ធប្រកបដោយសង្គតិភាពលើផលប៉ះពាល់ដែលអាចកើតចេញពីច្បាប់ឬបទប្បញ្ញត្តិ ឬការកែប្រែដែលគេចង់ធ្វើនោះតាមរយៈ៖

- ការវិភាគលើបញ្ហាដែលបានកើតឡើងដើម្បីកំណត់ បញ្ហាឲ្យបានច្បាស់លាស់។
- ការបង្កើតនូវជម្រើសដែលជាដំណោះស្រាយផ្សេងៗ (ច្បាប់ឬបទប្បញ្ញត្តិ ឬការកែប្រែដែលគេចង់ធ្វើនោះ) ចំពោះ បញ្ហាដែលបានកំណត់ខាងលើ និង
- ការពិនិត្យ និងវាស់វែងនូវតម្លៃត្រូវចំណាយ (Costs) និងផលប្រយោជន៍ (Benefits) ដែលអាចមាន របស់ច្បាប់ ឬបទប្បញ្ញត្តិ ឬការកែប្រែដែលគេចង់ធ្វើនោះ ព្រមទាំងជម្រើសជាដំណោះស្រាយផ្សេងៗដែលអាចរកឃើញ។

(២)-លើកកម្ពស់នូវគុណភាពនៃការសម្រេចចិត្តប្រកបដោយតុល្យភាពរវាងបញ្ហាដែលបានកើតឡើង ឬមានសក្តានុពលនឹងកើតឡើង ជាមួយនឹងផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមដែលអាចទទួលបាន និង

(៣)-ដើម្បីផ្តល់ព័ត៌មានទាំងនេះដល់អ្នកធ្វើការសម្រេចចិត្ត (Decision Maker)។

ក្នុងការអនុវត្ត RIA គេអនុលោមទៅតាមជំហានធំៗចំនួន ៧ ដូចខាងក្រោម៖

១- ការកំណត់បញ្ហា (Identify Problem)

២- ការកំណត់គោលបំណង(Identify Objectives)

៣- ការកំណត់ជម្រើសនានាដែលជាដំណោះស្រាយ (Identify Options)

៤- ការវិភាគលើផលប៉ះពាល់ធៀបនឹងផលប្រយោជន៍នៃជម្រើសនីមួយៗ (Costs and Benefits Analysis)

៥- ការប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធ ( Stakeholder Consultation[4])

៦- ការកំណត់ជម្រើសដំណោះស្រាយដែលសមស្របបំផុត (Choose Recommended Option)

៧- ការអនុវត្ត និងការពិនិត្យឡើងវិញ (Implementation and Review)

ទោះជាយ៉ាងណាក៏ដោយ គួរកត់សម្គាល់ផងដែរថា មកដល់បច្ចុប្បន្ននេះ ពុំទាន់មានគំរូណាមួយនៃការអនុវត្ត RIA ដែលត្រូវបានកំណត់ឲ្យប្រើប្រាស់ជាអន្តរជាតិនោះទេ ។ គ្រាន់តែថា រាល់គំរូនីមួយៗចាំបាច់ត្រូវរួមបញ្ចូលនូវធាតុមួយចំនួនដូចជា ៖

[4] ការប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធ :គឺជាកិច្ចការដ៏សំខាន់ដែលគ្របដណ្តប់លើដំណើរទាំងមូលរបស់RIAពុំមែនមានទីតាំងដាច់ខាត តែនៅជំហានទី៥ទេ។ សេចក្តីពិស្តារមានពន្យល់ក្នុងផ្នែកខាងក្រោយ។

- ការកំណត់គោលបំណងឲ្យបានច្បាស់លាស់
- ការពិចារណាប្រើប្រាស់ជម្រើសផ្សេងៗ ក្រៅពីការបង្កើតច្បាប់ឬបទប្បញ្ញត្តិថ្មី ឬការកែប្រែណាមួយលើច្បាប់ឬបទប្បញ្ញត្តិដែលមានស្រាប់
- ការពិនិត្យនិងវាស់វែងថ្លៃចំណាយ ផលប្រយោជន៍ និងផលប៉ះពាល់ ព្រមទាំង
- ការប្រឹក្សាយោបល់ជាប្រព័ន្ធជាមួយអ្នកពាក់ព័ន្ធ ។

# ការវាយតម្លៃផលប៉ះពាល់នៃច្បាប់

## Regulatory Impact Assessment[5]




[5] ឯកសារបណ្ដុះបណ្ដាលរបស់ បណ្ឌិត Hari Setianto អ្នកជំនាញផ្នែកវាយតម្លៃ ផលប៉ះពាល់នៃច្បាប់ ប្រទេសឥណ្ឌូនេស៊ី ។

## ជំហានទី១ ៖ ការកំណត់បញ្ហា

(Identify Problem)

ការកំណត់បញ្ហាគឺជាដំណាក់កាលមួយដ៏សំខាន់ និងជាជំហានចម្បងដែលយើងត្រូវធ្វើការសិក្សាឲ្យបានល្អិតល្អន់ ប្រសិនបើយើងរកបញ្ហាមិនចំគោលដៅទេ នោះជំហានបន្តបន្ទាប់មកទៀតនឹងមិនមានឥទ្ធិពលដែលអាចធ្វើឲ្យបញ្ហានោះត្រូវបានលុបបំបាត់ឬកាត់បន្ថយបានទេ។ តើបញ្ហាពិតប្រាកដជាអ្វី ឬបណ្ដាលមកពីច្បាប់ដែលចែងនៅមានភាពខ្វះចន្លោះ ឬមួយមនុស្សជាអ្នកបង្ក (មិនចូលរួមអនុវត្តច្បាប់) ។

ជាទូទៅ ច្បាប់មួយចំនួននៅពេលដែលរដ្ឋាភិបាលបម្រុងប្រកាសឲ្យប្រើ ឬកំពុងតែដាក់ឲ្យអនុវត្ត ជានិច្ចកាលតែងតែជួបនូវបញ្ហាខ្លះៗដែលអាចនឹងកើតឡើង ។ ដូចនេះតើត្រូវយកច្បាប់មួយណាមកដោះស្រាយ ឬមួយក៏បញ្ហានោះអាចរលាយបាត់ទៅវិញដោយខ្លួនឯង ។

បើតាមទ្រឹស្ដី RIA បានបង្ហាញថា ធម្មជាតិនៃបញ្ហាគឺអាចបណ្ដាលមកពីទិដ្ឋភាពពីរ ៖ **ទីមួយ** ភាពបរាជ័យនៅក្នុងបរិយាកាសសង្គម (Market Failure)។ នេះមានន័យថា ច្បាប់ ឬ បទប្បញ្ញត្តិដែលមានជាធរមាន និងមានគុណភាពល្អផងនោះត្រូវបានដាក់ឲ្យអនុវត្ត ។ តែបញ្ហានៅត្រង់ថា អ្នកអនុវត្តច្បាប់ ឬសង្គមទាំងមូលទេដែលមិនចូលរួមអនុវត្តតាម។ ម្យ៉ាង

ទៀត នៅពេលមានបញ្ហាណាមួយកើតឡើងអ្នកអនុវត្តបែរជាធ្វើព្រងើយ មិនចូលរួមដោះស្រាយទៅវិញ ។ **ទីពីរ** ភាពបរាជ័យខាង បទប្បញ្ញត្តិ (Government Failure) មានន័យថា ច្បាប់ដែល ដាក់ឲ្យអនុវត្ត មិនស្របតាមស្ថានភាពជាក់ស្តែង ឬមិនបម្រើ ឲ្យផលប្រយោជន៍សាធារណៈ (ច្បាប់ពុំមានគុណភាព) ហើយ ជួនកាលច្បាប់នោះនៅមានចំនុចចន្លោះប្រហោងដែលមិនអាច ដោះស្រាយបញ្ហាដែលកើតក្នុងសង្គមបានអស់ ។ ជាងនេះ ទៅទៀត មានពេលខ្លះបញ្ហាតូចតាចមួយចំនួនដែលគេអាច ដោះស្រាយត្រឹមកម្រិតតូច (សេចក្តីណែនាំផ្សេងៗ) ប៉ុន្តែ បែរជាប្រើច្បាប់ដែលមានទំហំធំ ដើម្បីដោះស្រាយបញ្ហាតូច ទៅវិញ ។

ក្នុងជំហានដំបូង «ការកំណត់បញ្ហា» ចំពោះច្បាប់ដែលមានស្រាប់ (Relevant Regulation) ត្រូវគិតថា ច្បាប់ដែលមានស្រាប់ អាចដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាពបានកម្រិតណា ហើយប្រសិនជាកែសម្រួលច្បាប់ដែលកំពុងដាក់ឲ្យអនុវត្ត តើអាចដោះស្រាយបញ្ហាដែលកំពុងកើតនោះបានដែរឬទេ?

នៅក្នុងជំហាននេះ បើយើងចង់កំណត់បញ្ហាឲ្យកាន់តែស៊ីជម្រៅ គឺមិនត្រឹមតែមើលលើសកម្មភាពដែលស្តែងចេញមកខាងក្រៅនោះទេ ប៉ុន្តែ ថែមទាំងមើលទៅលើឥរិយាបថនៃ

បញ្ហាដែលជាឫសគល់នៃបញ្ហានោះថែមទៀតផង ។ ការពិតរាល់បញ្ហាទាំងអស់គឺមានសញ្ញារបស់វា ទើបស្តែងចេញមកជាសកម្មភាព។ ហេតុនេះ យើងត្រូវយល់អំពីឥរិយាបថស្នូលនៃបញ្ហាជាមុនសិន ដែលឥរិយាបថនោះអាចជាទង្វើរបស់មនុស្សមួយក្រុម ឬសហគមន៍ទាំងមូលដែលបង្កើតឲ្យទៅជាបញ្ហា ។ ដូច្នេះ ការដឹងច្បាស់អំពីឫសគល់នៃបញ្ហា និងទង្វើរបស់អ្នកប្រព្រឹត្តគឺមានសារសំខាន់ណាស់ ដែលធ្វើឲ្យមានភាពងាយស្រួលក្នុងការរកវិធានការតាមផ្លូវច្បាប់ដើម្បីកែប្រែឥរិយាបថខុសឆ្គងទាំងនោះ ។

ឧទាហរណ៍ក្នុងតារាងខាងក្រោមនេះ បង្ហាញអំពីបញ្ហាដែលកើតឡើងដោយសារទង្វើរបស់មនុស្ស ហើយត្រូវបានសន្មត់ថាជាសូចនាករ (Indicator) ក្នុងការវាស់វែង ។

**តារាង(ក)**

| បញ្ហា | ទង្វើ (*នរណាធ្វើអ្វី?*) |
|---|---|
| ទំនិញមិនមានសុវត្ថិភាព | រោងចក្រផលិតទំនិញមានគ្រោះថ្នាក់ ខូចគុណភាព |
| ទឹកទន្លេត្រូវបានបំពុល | រោងចក្រនៅតាមមាត់ទន្លេបញ្ចេញជាតិពុលច្រើនទៅក្នុងទឹក |
| ស្ទះចរាចរណ៍ | អ្នកបើកបរគ្មានសណ្តាប់ធ្នាប់ មិនគោរពគ្នាទៅវិញទៅមក |
| មានសំរាមច្រើននៅមុខផ្ទះរបស់ប្រជាពលរដ្ឋ | អ្នកប្រមូលសំរាម មិនបានមកយកទៀងទាត់-ធ្វេសប្រហែស |

ក្នុងតារាងខាងលើអ្នកវិភាគអាចរកឃើញនូវហេតុផល ដែលនាំឲ្យមានបញ្ហា និងទាមទារឲ្យអ្នកវិភាគកំណត់ឲ្យបាន ច្បាស់លាស់នូវគោលបំណងដើម្បីដោះស្រាយបញ្ហា ។

នៅជំហានបន្ទាប់ នឹងមានពន្យល់អំពីការកំណត់នូវ គោលបំណងនៃការធ្វើវិភាគ ។

## ជំហានទី២ ៖ ការកំណត់គោលបំណង

## (Define Objectives)

ជំហានទី១ យើងបានរកឃើញបញ្ហាជាគន្លឹះសម្រាប់ធ្វើការវិភាគ ។ ជំហាននេះ តម្រូវឲ្យមានការកំណត់ច្បាស់ នូវគោលបំណង ថាតើយើងចង់បានអ្វី និងត្រូវដោះស្រាយចំណុចអ្វីខ្លះ? ឬមួយកែតម្រូវច្បាប់ទាំងមូល ឬក៏គ្រាន់តែកែសម្រួលនៅលើផ្នែកណាមួយនៃច្បាប់ (ច្បាប់ធរមាន) ។

ការកំណត់នូវគោលបំណងឲ្យបានជាក់លាក់ គឺអាចជៀសវាងនូវមន្ទិល ដែលអាចនាំឲ្យការសិក្សានោះមានភាពមិនច្បាស់លាស់មិនចំខ្លឹមសារ និងចំពោះបញ្ហាជាក់ស្តែងដែលបាន កើតឡើង ។ ខ្លឹមសាររបស់ច្បាប់មួយទាំងមូល យើងមិនអាច ធ្វើការវាយតម្លៃទៅលើគ្រប់ទិដ្ឋភាពទាំងអស់នៃច្បាប់បានទេ ដោយហេតុថា មានផ្នែកណាមួយដែលពុំស្របតាមស្ថានភាព សង្គមបច្ចុប្បន្ន និងច្បាប់មានវិសាលភាពធំទូលាយពេក ។ ដូច្នេះ គេអាចធ្វើការសិក្សាទៅលើខ្លឹមសារនៃមាត្រាសំខាន់ៗ ដែលពាក់ព័ន្ធនឹងបញ្ហាដែលយើងចង់ដោះស្រាយ បន្ទាប់មក ធ្វើរបាយការណ៍វាយតម្លៃសរុបនៅលើទិដ្ឋភាពច្បាប់ទាំងមូលតែម្តង។

ការកំណត់គោលបំណងក្នុងជំហាននេះ តែងតែមានការភ័ន្តច្រឡំជាមួយនឹងជំហានទី៣ អំពីការកំណត់ជម្រើស ។

ដូចនេះ ប្រការគួរឲ្យកត់សម្គាល់ អ្នកវិភាគត្រូវចាប់អារម្មណ៍ចំពោះពាក្យ «**អ្វី**» «What» តើយើងចង់បានអ្វី? និងយើងចង់ដោះស្រាយបញ្ហាអ្វី?

ផ្ទុយទៅវិញ បើយើងកំណត់គោលបំណងជាវិធានការ ឬវិធីដោះស្រាយតាម«**របៀបណា**» «How» នោះ គឺជាការយល់ខុសស្រឡះទៅវិញដូចដែលបានពោលមកពីខាងដើម។

ឧទាហរណ៍ដែលបង្ហាញក្នុងតារាង(ក) អំពីការកំណត់គោលបំណង (Define Objectives) គឺមានដូចជា ទី១-ចង់ឲ្យរោងចក្រផលិតទំនិញមានសុវត្ថិភាព ទី២-ចង់បានទឹកមានគុណភាពប្រសើរជាងមុន និងទី៣-ចង់កាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍ ។

## ជំហានទី៣ ៖ ការកំណត់ជម្រើសដំណោះស្រាយ (Identify Options)

ជំហាននេះតម្រូវឲ្យអ្នកវិភាគ RIA ព្យាយាមស្វែងរកនូវជម្រើសមួយចំនួនដែលអាចជាមធ្យោបាយរបៀបណា«How» ដើម្បីដោះស្រាយបញ្ហា និងសម្រេចគោលបំណងដែលយើងចង់បាន ដូចបានកំណត់ក្នុងជំហានទី២ ។ តើមានដំណោះស្រាយបែបណាខ្លះ?និងធ្វើដូចម្តេចដើម្បីសម្រេចគោលបំណង ដែលបានកំណត់?

នៅក្នុងការកំណត់ជម្រើសដំណោះស្រាយ អ្នកវិភាគត្រូវគិតអំពីជម្រើសនានាថាតើអាចដោះស្រាយបញ្ហានោះបានដែរឬទេ ក្រៅពីការធ្វើច្បាប់ ដោយចាត់ទុក *ការបង្កើតច្បាប់ឬបទប្បញ្ញត្តិជាជម្រើសក្រោយគេ* ។ ប្រសិនបើ វិធីផ្សេងៗ នៅតែពុំអាចដោះស្រាយបញ្ហាបាន នោះគឺគេចមិនផុតពីការចេញច្បាប់ដើម្បីដាក់ឲ្យអនុវត្តឡើយ។

ឧទាហរណ៍ខាងក្រោមនេះនឹងបង្ហាញអំពីការវិភាគលើជម្រើសនានាដើម្បីដោះស្រាយបញ្ហាការបំពុលទឹកទន្លេ ដែលបណ្តាលមកពីវត្តមាននៃរោងចក្រនៅតាមមាត់ទន្លេដែលបានបង្ហូរកាកសំណល់ចូលទៅក្នុងទឹក។

មានជម្រើស ៣ យ៉ាងសំខាន់ៗ គឺ ៖

1- ជម្រើសមិនធ្វើអ្វីសោះ (Doing nothing)

ដោយទុកឲ្យសកម្មភាពបង្ហូរជាតិពុលរបស់រោងចក្រទៅក្នុងទន្លេនៅបន្តដំណើរការជាធម្មតា។ លទ្ធផលគឺវាអាចបណ្តាលឲ្យទឹកខូចគុណភាព បរិមាណត្រីរងការប៉ះពាល់ និងទឹកមានជាតិពុល ជាដើម ។ ជូនកាល អ្នកវិភាគអាចយកជម្រើសមិនធ្វើអ្វីសោះ (Doing Nothing) មានន័យថាច្បាប់ ឬលិខិតបទដ្ឋានទាំងអស់គឺរក្សាក្នុងស្ថានភាពដដែល ។ ករណីនេះ តើបញ្ហាដែលបានកើតឡើង នឹងត្រូវបន្តកាន់តែធ្ងន់ធ្ងរថែមទៀត ឬក៏បញ្ហាទាំងអស់នោះអាចត្រូវបានកាត់បន្ថយ ឲ្យស្ថិតនៅក្នុងកម្រិតធូរស្រាលជាងមុន ។

2- ជម្រើសមិនមែនជាច្បាប់ឬបទប្បញ្ញត្តិ (Non-Regulatory)

ក-ការអប់រំ និងយុទ្ធនាការផ្សព្វផ្សាយ

ក្នុងជម្រើសនេះ គេត្រូវធ្វើការអប់រំ និងផ្សព្វផ្សាយដល់បណ្តារោងចក្រទាំងអស់នៅតាមដងទន្លេ ដើម្បីឲ្យយល់ដឹងអំពីគុណវិបត្តិនៃការបង្ហូរកាកសំណល់ ដែលវាធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹក និងការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នោះ ។

នៅពេលដែលពួកគាត់បានយល់ដឹងអំពីផលវិបាកនៃការបំពុលនោះ ធ្វើឲ្យគាត់(ម្ចាស់រោងចក្រ) អាចមានវិធានការដើម្បីការពារ និងកាត់បន្ថយគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋដែលរស់នៅក្បែរតំបន់នោះ។

**ខ-ការលើកទឹកចិត្តចំពោះរោងចក្រ**

ក្នុងជម្រើសនេះ គេបានបង្កើតនូវយន្តការមួយចំនួនដូចជា ការលើកលែងពន្ធ និងបន្ធូរបន្ថយពន្ធត្រឹមកម្រិតណាមួយដល់រោងចក្រណាដែលមានវិធានការល្អ ដើម្បីទប់ស្កាត់មិនឲ្យមានជាតិពុលហូរចូលទៅក្នុងទន្លេ ដូចជាបង្កើតឲ្យមានអាងចម្រោះកាកសំណល់សាមញ្ញមួយ ដែលអាចកាត់បន្ថយនូវកម្រិតជាតិពុលបានជាមធ្យម ។ ផ្ទុយទៅវិញ វិធានការនេះរដ្ឋាភិបាលត្រូវបាត់បង់ចំណូលពន្ធមួយផ្នែក ។

**គ-ការឧបត្ថម្ភធនដល់រោងចក្រ**

ការផ្តល់ឧបត្ថម្ភធនដល់រោងចក្រ ដើម្បីបំពាក់នូវប្រព័ន្ធទំនើបសម្រាប់ចម្រោះកាកសំណល់ និងជាតិពុលនានា គឺជាវិភាគទានមួយដ៏ធំធេងរបស់រដ្ឋាភិបាលក្នុងការចូលរួមចំណែក លើកកំពស់សុខមាលភាពសង្គម ។ តាមរយៈវិធានការនេះ រដ្ឋអាចផ្តល់ជាការលើកលែងនូវពន្ធនាំចូលទាំងស្រុងក្នុងការ នាំចូលគ្រឿងម៉ាស៊ីន និងឧបករណ៍ផ្សេងៗ ឬក៏បំពាក់

នូវប្រព័ន្ធ ចម្រោះកាកសំណល់ដល់រោងចក្រតែម្តង ។ មធ្យោបាយនេះ រដ្ឋនឹងត្រូវចំណាយថវិកាអស់យ៉ាងច្រើន ។

**3-ជម្រើសជាច្បាប់ឬបទប្បញ្ញត្តិ(Regulatory)**

ជម្រើសទាំងពីរខាងលើគឺជាជម្រើសទន់ភ្លន់ ដែលត្រូវបានយកមកប្រើជាគោលនយោបាយ ប៉ុន្តែ ជម្រើសទាំងនេះមិនមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ឡើយ ។ ដូច្នេះវិធានការចុងក្រោយនោះរដ្ឋាភិបាលត្រូវបង្កើតច្បាប់តែម្តង ដោយតម្រូវឲ្យរោងចក្របំពាក់នូវម៉ាស៊ីនចម្រោះដោយខ្លួនឯង ។

ដំណើរការតាក់តែងច្បាប់ នឹងធ្វើឲ្យរោងចក្រចំណាយថវិកាលើការផ្តល់អ្នកជំនាញការដើម្បីសិក្សា និងស្រាវជ្រាវរកផលប៉ះពាល់ផ្សេងៗ។ ម្យ៉ាងវិញទៀត នៅពេលដែលច្បាប់ត្រូវបានប្រកាសឲ្យប្រើ រោងចក្រត្រូវចូលរួមអនុវត្តច្បាប់ និងត្រូវចំណាយច្រើន រាប់តាំងពីនីតិវិធីរដ្ឋបាលនានា រហូតដល់ការទិញសម្ភារៈឧបករណ៍មកបំពាក់ ។ ប្រសិនបើ រោងចក្រគោរពតាមបទប្បញ្ញត្តិនេះ ជាលទ្ធផលគឺអាចកាត់បន្ថយបញ្ហាប៉ះពាល់សុខភាពបានច្រើន ។

ជម្រើសទាំងប៉ុន្មានខាងលើគឺជាឧទាហរណ៍ដែលបានលើកយកមកបង្ហាញដោយប្រើប្រាស់នូវទ្រឹស្តី RIA សម្រាប់ធ្វើការវិភាគរកឫសគល់នៃបញ្ហា ព្រមទាំងកំណត់នូវវិធានការដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាព ។

## ជំហានទី៤ : ការវិភាគលើផលប៉ះពាល់ធៀបនឹង ថ្លៃចំណាយនៃជម្រើសនីមួយៗ

### Impact (cost/benefits) Analysis

នៅក្នុងជំហាននេះ ដើម្បីជាមូលដ្ឋានក្នុងការវិភាគលើផល ចំណេញនិងការចំណាយ ជាទូទៅត្រូវផ្តោតជាចម្បងលើកត្តា៣ សំខាន់ៗគឺ កត្តាសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ប៉ុន្តែ បើតាមយោបល់អ្នកសិក្សាស្រាវជ្រាវផ្សេងទៀតបានពន្យល់ថា បន្ថែមលើកត្តា ទាំងបីខាងលើ អ្នកវិភាគត្រូវគិតគូរចំពោះវិស័យឯកជន ក៏ដូចជា បញ្ហាផ្សេងៗដែលប៉ះពាល់ដល់រដ្ឋាភិបាលផងដែរ ។

ការវិភាគនេះត្រូវផ្សារភ្ជាប់ទាំងរវាងផលចំណេញ និង ការចំណាយទៅនឹងទំហំនៃបញ្ហាដែលបានកើតឡើង ថាតើវាសមាមាត្រ ឬសមមូលជាមួយវិសាលភាពនៃបញ្ហាដែរឬទេ? ជាក់ស្តែង ប្រសិនបើបញ្ហានោះតូចតាច ការវិភាគក៏ត្រូវធ្វើនៅក្នុងកម្រិតតូចដែរ ។ ដូច្នេះយើងអាចប្រើប្រាស់វិធីសាស្រ្តវិភាគតាមបែបគុណភាព (Qualitative Analysis) គឺគ្រប់គ្រាន់សម្រាប់សេចក្តីត្រូវការរបស់យើង ។ ការវិភាគបែបគុណភាពត្រូវផ្តោតជាសំខាន់ទៅលើចំណុចល្អ និង ចំណុចអាក្រក់នៅក្នុងជម្រើសនីមួយៗទាក់ទងនឹងថ្លៃចំណាយនិងផលចំណេញ ថាតើមានចំនួន*ច្រើន បង្គួរ មធ្យម* ឬ*តិច* ត្រឹមកម្រិតណា។

ផ្ទុយទៅវិញ ប្រសិនបើអ្នកវិភាគចង់ដឹងលទ្ធផលឲ្យស៊ីជម្រៅ និងជាក់ស្តែងថែមទៀតនោះ ដាច់ខាតត្រូវតែមានពេលវេលាសម្រាប់ការសិក្សា ស្រាវជ្រាវគ្រប់គ្រាន់ ។ ការវិភាគបែបនេះហៅថាវិធីសាស្ត្រវិភាគបែបបរិមាណ (Quantitative Analysis) ពោលគឺ ចេញជាតួលេខជាក់ស្តែងតែម្តង ។

ជាទូទៅ ការវិភាគលើផលប៉ះពាល់ មិនផ្តោតខ្លាំងទៅលើផ្នែកបរិមាណដែលបង្ហាញជា *តួលេខ* ទេ គឺយើងគ្រាន់តែពិចារណាទៅលើផ្នែកគុណភាព (*ច្រើន បង្គួរ មធ្យម ឬតិច* ) តែប៉ុណ្ណោះ។

ការកំណត់អំពីផលចំណេញ និងការចំណាយគេក៏ត្រូវកំណត់ថានរណាខ្លះជាអ្នកពាក់ព័ន្ធ និងនៅពេលដែលច្បាប់ដាក់ឲ្យអនុវត្ត តើមាននរណាខ្លះដែលអាចរងផលប៉ះពាល់។

ឧទាហរណ៍ដែលបានលើកមកបង្ហាញនៅក្នុងជំហានទី៣ ដែលបង្ហាញអំពីជម្រើសដំណោះស្រាយមួយចំនួននោះ គឺដាច់ខាតត្រូវការថ្លៃចំណាយដើម្បីការពារសុខភាពប្រជាជនដែលរស់នៅជិតតំបន់នោះ។ ការចំណាយទាំងនោះនឹងត្រូវបានគិតគូរដោយគិតចាប់ពីចំណាយសម្រាប់ការចាប់ផ្តើមធ្វើអាជីវកម្ម រួមមាន ការចុះបញ្ជីពាណិជ្ជកម្ម ការដោះដូរទំនិញការដឹកជញ្ជូន ការបង់ពន្ធផ្សេងៗ ព្រមទាំង ការចំណាយរបស់អ្នកប្រើប្រាស់ដើម្បីទិញទំនិញ ឬសេវាកម្ម ។ល។ ដោយឡែក

ប្រជាជនក្នុងសហគមន៍ក៏ត្រូវបង់ថ្លៃចំណាយក្នុងការព្យាបាលសុខភាពដែលបណ្តាលមកពីជាតិពុលនៃកាកសំណល់នានាផងដែរ ។

ក្រៅពីនេះ រដ្ឋាភិបាលត្រូវចំណាយទៅលើយុទ្ធនាការផ្សព្វផ្សាយ និងការអប់រំ ក៏ដូចជាសេវាត្រួតពិនិត្យផ្សេងៗដល់ភាគីពាក់ព័ន្ធទាំងឡាយ ។

ការវិភាគលើផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមាន (ផលចំណេញ និងការចំណាយ) មានកម្មវត្ថុមួយចំនួនដែលត្រូវពិចារណាគឺ ៖

**ទី១** មានផលប្រយោជន៍ ឬត្រូវចំណាយ អ្វីខ្លះ?

**ទី២** តើអ្នកណាទទួលផលចំណេញ ឬត្រូវចំណាយ? ចំណុចទី១ និងទី២ គេអាចប្រើការវិភាគតាម*វិធីគុណភាព* ដោយពឹងផ្អែកតែនៅលើឯកសារដែលមានស្រាប់ (Secondary Data) និងព័ត៌មាននានាដែលពាក់ព័ន្ធ គួបផ្សំនឹងចំណេះដឹង និងបទពិសោធន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ គឺពុំទាន់ចូលជ្រៅដល់ តួលេខ ឬត្រូវការអ្នកជំនួយពីខាងក្រៅនៅឡើយទេ។

**ទី៣** តើមានអ្វីខ្លះដែលអាចធ្វើការ**វាស់វែង**បានជាផលចំណេញ និងថ្លៃចំណាយ?

**ទី៤** រកឲ្យឃើញនូវ**ស្ថានភាពជាក់ស្តែង** មុនពេលដែលយើងដាក់ឲ្យអនុវត្តច្បាប់ ឬដាក់ចេញវិធានការផ្សេងៗ ។

**ទី៥** សង្កេតអំពីការប្រែប្រួលនានាដែលអាចកើតមានថាតើបញ្ហា**នៅតែបន្តកើតឡើង** ឬថយចុះ ក្រោយពេលដែលវិធានការ (ច្បាប់និងឬបទប្បញ្ញត្តិ) នោះដាក់ចេញឲ្យអនុវត្ត ។ ដូច្នេះ គេត្រូវគណនា និងបង្ហាញនូវតួលេខ (Quantitative)។

**ទី៦** ត្រូវធ្វើការគណនា**តួលេខ(បរិមាណ)** ទៅជាចំនួនទឹកប្រាក់ ។ ឧទាហរណ៍ នៅមន្ទីរពេទ្យមានអ្នកជំងឺសម្រាកព្យាបាលចំនួន៨០នាក់ ប្រសិនបើគិតជាថវិកាតើមន្ទីរពេទ្យត្រូវចំណាយអស់ចំនួនប៉ុន្មាន?

៣-<u>ការសិក្សាស្ថានភាព Baseline</u>

ក្នុងការគណនា «ផលប្រយោជន៍( Benefits)» នៃជម្រើសដំណោះស្រាយនីមួយៗ (ដែលបានកំណត់ក្នុងជំហានទី៣ខាងលើ) នៅពេលវិភាគផលប៉ះពាល់( Impact Analysis) នៃជម្រើសទាំងនោះ មានចំណុចសំខាន់មួយដែលត្រូវយកចិត្តទុកដាក់ ដើម្បីចៀសវាងការសន្និដ្ឋានខុស។ ចំណុច ដ៏សំខាន់នោះគឺ *«ការសិក្សាស្ថានភាព Baseline របស់សូចនាករនៃផលប្រយោជន៍(Benefit Indicator)»* ដែលជាការសិក្សាអំពីស្ថានភាពរបស់សូចនាករនៃផលប្រយោជន៍(ណាមួយ) ក្នុង

ករណីពុំមាន(Without)[6] ការចាត់វិធានការដោយជម្រើសដំណោះស្រាយដែលបានកំណត់នោះ។

ការសិក្សាអំពីស្ថានភាពនេះ ចាំបាច់ត្រូវធ្វើចំពោះសូចនាករនៃផលប្រយោជន៍(ណាមួយ) ដែលមានចរិតប្រែប្រួលជានិន្នាការ(Trend) ឡើង ឬចុះ ទៅតាមដំណើរនៃពេលវេលា ដើម្បីមើលអោយឃើញពី *ទម្រង់ពិតប្រាកដរបស់សូចនាករនៃផលប្រយោជន៍* នោះជាមុនសិន ទើបយើងអាចគណនាផលប្រយោជន៍នៃជម្រើសដំណោះស្រាយនោះ ( ដែលមានសូចនាករផលប្រយោជន៍មានចរិតជានិន្នាការ) បានត្រឹមត្រូវ ។ ព្រោះសូចនាករបែបនេះ(ចរិតប្រែប្រួលជានិន្នាការឡើង ឬចុះ)

---

[6] ពាក្យថា ក្នុងករណី -មាន ឬ ពុំមាន(With or Without)- : គឺជាពាក្យបច្ចេកទេសត្រឹមត្រូវសម្រាប់ប្រើពណ៌នា ឬពន្យល់អំពី Baseline។ សូមជៀស វាងប្រើពាក្យផ្សេងៗ ដែលហាក់ដូចជាបញ្ជាក់ន័យដូច ឬស្រដៀងគ្នា ប៉ុន្តែអត្ថន័យរបស់វាខុសគ្នាស្រឡះ ហើយធ្វើអោយមានការយល់ដឹងខុសទៀតផង។ *ឧទាហរណ៍៖ ពាក្យថា -មុនពេល ឬ ក្រោយពេល(Before or After)-។ ប្រសិនបើយើងប្រើពាក្យនេះ→....ការគណនាផលប្រយោជន៍របស់ជម្រើសដំណោះស្រាយទី២ ដោយប្រៀបធៀបរវាងស្ថានភាពរបស់សូចនាករនៃផលប្រយោជន៍(ចំនួនត្រី)នៅមុនពេល និងក្រោយពេលមានការចាត់វិធានការណ៍ដោយជម្រើសនេះ បង្ហាញថា ស្ថានភាពរបស់សូចនាករនៃផលប្រយោជន៍នោះកាន់តែធូរឡើង...។ (សូមស្វែងយល់បន្ថែមក្នុងឧទាហរណ៍អំពីការសិក្សាស្ថានភាព Baseline ខាងក្រោម ត្រង់ចំណុចការបកស្រាយទី២)*

យើងពុំអាចចាប់យកស្ថានភាព របស់វានៅ មុនពេល ប្រើជម្រើសដំណោះស្រាយ(ណាមួយនោះ) មកប្រៀបធៀបជាមួយស្ថានភាពក្រោយពេលប្រើជម្រើសដំណោះស្រាយ ហើយធ្វើការសន្និដ្ឋានអំពីបរិមាណរបស់វា( ថាវិជ្ជមាន=កើន ឬអវិជ្ជមាន=ថយ)ភ្លាមបានទេ។ អ្នកវិភាគត្រូវសិក្សាពីនិន្នាការវិវត្តន៍របស់សូចនាករនេះ ក្នុងគម្លាតពេលវេលាមួយសមរម្យ ក្នុងករណីពុំមាន(Without) ការចាត់វិធានការណ៍ដោយជម្រើសដំណោះស្រាយ(ហៅថាការសិក្សាស្ថានភាព Baseline)ជាមុនសិន បន្ទាប់មកទើបសិក្សាពីស្ថានភាពរបស់វាក្នុងករណី មាន ( With )ការចាត់វិធានការដោយជម្រើសដំណោះស្រាយនោះ ក្នុងគម្លាតពេលវេលាដូចគ្នា ហើយយកស្ថានភាពទាំងពីរដែលបានសិក្សាមកប្រៀបធៀបគ្នា ទើបអាចទាញជាសេចក្តីសន្និដ្ឋានដ៏ត្រឹមត្រូវមួយបាន *ថាតើសូចនាករនោះវិជ្ជមាន ឬអវិជ្ជមាន ក៏ដូចជា ថាតើជម្រើសដំណោះស្រាយនោះមានផ្តល់ផលប្រយោជន៍ ឬមិនមាន។*

⇨ **ឧទាហរណ៍:** ដោយមើលឃើញបញ្ហាបំពុលទឹកទន្លេមេគង្គ ដែលកាន់តែធ្ងន់ធ្ងរទៅជាលំដាប់ បណ្តាលមកពីរោង

ចក្រមួយចំនួននៅតាមដងទន្លេនេះបញ្ចេញកាកសំណល់បំពុលរបស់ខ្លួនចូលក្នុងទន្លេ នៅឆ្នាំ២០០៤រដ្ឋាភិបាលគ្រោងនឹងចេញ <u>បទប្បញ្ញត្តិមួយ</u>[7] ដើម្បីតម្រូវអោយបណ្តារោងចក្រទាំងនោះបំពាក់ម៉ាស៊ីនត្រួតពិនិត្យ និងកែច្នៃកាកសំណល់របស់ខ្លួន។ *(បញ្ជាក់ ៖ ឧទាហរណ៍នេះ ផ្តល់ជម្រើសដំណោះស្រាយតែមួយប៉ុណ្ណោះ)*

*សម្មតិកម្ម១៖ ប្រសិនបើ មានជម្រើសដំណោះស្រាយដោយការចេញច្បាប់នេះ <u>បរិមាណត្រី</u>[8] នៅក្នុងទន្លេ ក្នុងចន្លោះឆ្នាំ២០០៤-២០០៨ គឺ៖*

| *ឆ្នាំ* | *២០០៤* | *២០០៥* | *២០០៦* | *២០០៧* | *២០០៨* |
|---|---|---|---|---|---|
| *ត្រី/តោន* | *៦០០* | *៥០០* | *៥០០* | *៤០០* | *៤០០* |

[7] បទប្បញ្ញត្តិ ៖ គឺជាជម្រើសដំណោះស្រាយមួយ ចំពោះបញ្ហា។

[8] បរិមាណត្រី ៖ គឺជាសូចនាករមួយនៃផលប្រយោជន៍ (របស់ជម្រើសដំណោះស្រាយខាងលើ) ដែលមានចរិតជានិន្នាការ(ចុះ)។

*សម្មតិកម្ម២៖ ប្រសិនបើ ពុំមានជម្រើសដំណោះស្រាយ ដោយការចេញច្បាប់នេះ បរិមាណត្រីនៅ ក្នុងទន្លេ ក្នុងចន្លោះឆ្នាំ២០០៤-២០០៨ គឺ៖*

| *ឆ្នាំ* | *២០០៤* | *២០០៥* | *២០០៦* | *២០០៧* | *២០០៨* |
|---|---|---|---|---|---|
| *ត្រី/តោន* | *៦០០* | *៣៥០* | *៣០០* | *២០០* | *១០០* |

⇨ <u>ការបកស្រាយ:</u>

១- ប្រសិនបើយើងមើលតែលើសម្មតិកម្ម១ ៖ យើងអាចនឹងធ្វើការសន្និដ្ឋានថា វិធានការដែលតម្រូវអោយមានបទប្បញ្ញត្តិនេះ ជាវិធានការដែលពុំមានប្រសិទ្ធភាព ឬផលប្រយោជន៍ទេ ដោយយើងគណនាឃើញថា ក្រោយពេលមានវិធានការណ៍នេះនៅឆ្នាំ២០០៤ រហូតដល់ឆ្នាំ២០០៨ បរិមាណត្រីបានថយចុះពី៦០០តោន ដល់៤០០តោន។

២- ប៉ុន្តែផ្ទុយទៅវិញ បើយើងសិក្សាស្ថានភាព Baseline ជាមុន ដោយពុំធ្វើការសន្និដ្ឋានផ្អែកតាមការគណនាត្រង់ៗនូវបរិមាណត្រីក្រោយពេល[៩] មានវិធានការណ៍ ពោលគឺយើងសិក្សាពីនិន្នាការនៃបរិមាណត្រី ក្នុងករណីពុំមានវិធានការណ៍ រួចប្រៀបធៀបជាមួយនិន្នាការនៃបរិមាណត្រីក្នុងករណីមានវិធានការណ៍ នោះយើងនឹងឃើញថា៖

- បើពុំមានវិធានការ ៖ ក្នុងចន្លោះឆ្នាំ២០០៤-២០០៨ បរិមាណត្រីថយចុះពី ៦០០តោន ដល់១០០តោន
- បើមានវិធានការ ៖ ក្នុងចន្លោះឆ្នាំ២០០៤-២០០៨ បរិមាណត្រីថយចុះពី៦០០តោន ដល់៤០០តោន

---

[៩] ដូចមានបញ្ជាក់ក្នុងចំនុចសំគាល់ទី៥ខាងលើខ្លះហើយ ការភ័ន្តច្រឡំក្នុងបរិបទនៃការគិតគូរអំពីស្ថានភាព Baseline ជាធម្មតាបណ្តាលមកពីការគិតគូរដោយប្រើទស្សនៈផ្តោតលើស្ថានភាពមុនពេល ឬ ក្រោយពេល ការចាត់វិធានការណ៍ដោយជម្រើសដំណោះស្រាយណាមួយ ជាក់ស្តែងដូចឃើញក្នុងឧទាហរណ៍នេះស្រាប់។

→ សន្និដ្ឋាន ៖ បើមានវិធានការណ៍ បរិមាណត្រីនៅតែមាននិន្នាការថយចុះដដែល ប៉ុន្តែការថយចុះនេះតិចជាងការថយចុះក្នុងករណីពុំមានវិធានការណ៍ ។ ដូច្នេះ វិធានការណ៍នេះពិតជាមានប្រសិទ្ធភាព ហើយអាចសន្សំត្រីបាន៣០០តោន ក្នុងគម្លាតពេលពីឆ្នាំ២០០៤ ដល់២០០៨។

⇨ <u>ដ្យាក្រាមបង្ហាញ</u> ៖



## ជំហានទី៥ : ការប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធ
## (Stakeholders Consultation)

ការប្រឹក្សាយោបល់គឺជាមធ្យោបាយ ឬឧបករណ៍យ៉ាងសំខាន់ ដែលអាចជួយឲ្យអ្នកវិភាគទទួលបាននូវទស្សនៈទូលំទូលាយក្នុងការវិភាគច្បាប់ និងឬបទប្បញ្ញត្តិ ដោយហេតុថាអ្នកពាក់ព័ន្ធអាចមានគំនិតផ្សេងពីអ្វីដែលអ្នកវិភាគមាន និងបានរកឃើញ ។ អ្នកវិភាគអាចទទួលយកទស្សនៈរបស់ភាគីពាក់ព័ន្ធទាំងនោះប៉ុន្តែ ដាច់ខាតត្រូវចៀសវាងនូវការស្នើសុំឲ្យមានការសម្របសម្រួលពីអ្នកពាក់ព័ន្ធ។ គំនិត ឬទស្សនៈរបស់ភាគីពាក់ព័ន្ធអាចយកមកបញ្ចូលក្នុងរបាយការណ៍វិភាគ RIA ពីព្រោះ ខ្លឹមសារច្បាប់និងឬបទប្បញ្ញត្តិមួយ មិនអាចបំពេញចិត្តចំពោះបុគ្គលគ្រប់ៗគ្នាបាននោះទេ ដោយសារតែបុគ្គលនីមួយៗ មានគំនិត និងការយល់ឃើញខុសៗគ្នា ។

ការសុំប្រឹក្សាយោបល់គួរធ្វើឲ្យបានលឿន ហើយត្រូវធ្វើចាប់តាំងពីជំហានដំបូង ។ ប៉ុន្តែ បើតាមបទពិសោធន៍ដែលបានអនុវត្តនៅប្រទេសឥណ្ឌូនេស៊ី គេចាប់ផ្តើមធ្វើការប្រឹក្សាយោបល់នៅជំហានទី៣ (*ការកំណត់ជម្រើសដំណោះស្រាយ*) ពីព្រោះរាល់ជំហានទាំងបីខាងដើមនេះមានលក្ខណៈពាក់ព័ន្ធគ្នា និងស្ថិតក្នុងបរិបទនៃការវិភាគតែមួយ ។

ក្នុងការអនុវត្ត បន្ទាប់ពីបានធ្វើការពិគ្រោះយោបល់រួច និងរកឃើញថា គំនិតរបស់ភាគីពាក់ព័ន្ធជាដំណោះស្រាយល្អ អ្នកវិភាគត្រូវបញ្ចូលបន្ថែមជាជម្រើស ព្រមទាំងបង្ហាញអំពីវិធីដែលត្រូវយកទៅអនុវត្ត ជាមួយនឹងការត្រៀមលក្ខណៈរួចជាស្រេចដើម្បីធ្វើការត្រួតពិនិត្យឡើងវិញនៅពេលដែលយើងដាក់ច្បាប់នោះឲ្យអនុវត្ត។

មុនពេលធ្វើការពិគ្រោះយោបល់ ត្រូវចាប់អារម្មណ៍អំពីភាគីគោលដៅដែលត្រូវធ្វើការពិគ្រោះយោបល់ជាមួយ ថាតើមានអ្នកណាខ្លះជាអ្នកពាក់ព័ន្ធនឹងបញ្ហាដែលបានកើតឡើង? បញ្ហាកើតឡើងជាទង្វើរបស់អ្នកណា? អ្នកណាខ្លះដែលរងគ្រោះដោយសារឥទ្ធិពលនៃបញ្ហា?

បន្ទាប់ពីបានកំណត់ក្រុមគោលដៅដែលត្រូវសាកសួររួចហើយ យើងត្រូវតែរៀបចំជាកំរងសំណួរដែលមានខ្លឹមសារពាក់ព័ន្ធនឹងបញ្ហា ដោយបត់បែនទៅតាមស្ថានភាពជាក់ស្តែង និងភាគីពាក់ព័ន្ធ។ ការរៀបចំកំរងសំណួរមានការលំបាក និងស្មុគ្រស្មាញដែលត្រូវគិតគូរឲ្យបានហ្មត់ចត់ ។ ជាមួយគ្នានេះត្រូវកំណត់ពេលវេលាឲ្យបានច្បាស់លាស់ ថាតើត្រូវការរយៈពេលសម្ភាសន៍មួយ ឬពីរសប្តាហ៍ ឬលើសពីនេះ។ មធ្យោបាយ ដែលល្អនោះគឺ យើងអាចជម្រាបជូនអំពីខ្លឹមសារច្បាប់ និងឬ បទប្បញ្ញត្តិ ក៏ដូចជា ឫសគល់នៃបញ្ហាជាមុនដល់

អ្នកពាក់ព័ន្ធ ដើម្បីឲ្យពួកគេបានត្រៀមគំនិតជាមុនគ្រប់ជ្រុងជ្រោយ ។

ការពិគ្រោះយោបល់ ក៏អាចឲ្យយើងដឹងនូវអ្វីដែលអាចកើតឡើងនៅពេលដែលច្បាប់ត្រូវបានដាក់ឲ្យអនុវត្ត ហើយយើងក៏អាចរៀបចំផែនការពិគ្រោះយោបល់សម្រាប់ប្រើប្រាស់ក្នុងរយៈពេលវែងថែមទៀតផង។

## ជំហានទី៦ : ការធ្វើសេចក្តីសន្និដ្ឋាន និង ការកំណត់ជម្រើសសមស្របបំផុត

(Choose Recommended Option)

ជំហាននេះ តម្រូវដល់អ្នកវិភាគធ្វើសេចក្តីសន្និដ្ឋានលើរបាយការណ៍នៃការវិភាគ RIA ដោយមានបញ្ជាក់អំពី**ជម្រើសដំណោះស្រាយ**ដ៏ប្រសើរបំផុត ។ អ្នកវិភាគត្រូវពន្យល់លំអិតនូវជម្រើសដែលល្អដែលនឹងត្រូវជ្រើសយក ដោយបង្ហាញអំពីសារសំខាន់ចាំបាច់ ព្រមទាំងទឡ្ហីករណ៍រឹងមាំដែលបង្ហាញអំពីផលប្រយោជន៍ធៀបនឹងការចំណាយ ។ម្យ៉ាងវិញទៀត ចំពោះជម្រើសដទៃទៀតដែលមិនបានជ្រើសយក ត្រូវបង្ហាញនូវ ចំណុចខ្វះខាត ឬផលចំណេញតិច ឬក៏ចំណាយច្រើន។ល។ ដែលជាមូលហេតុត្រូវបដិសេធចោល និងងាកទៅជ្រើសយក ជម្រើសដែលសមស្របបំផុតវិញនោះ ។

ប្រសិនបើ អ្នកវិភាគមានការលំបាកក្នុងការជ្រើសរើស និងថ្លឹងថ្លែងនូវជម្រើសពីរ ឬច្រើនដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ដោយសារតែការពិនិត្យលើផលចំណេញមានលក្ខណៈខុសគ្នាបន្តិចបន្តួចនោះ យើងត្រូវពិចារណានៅលើ**ការចំណាយថ្លៃដើម** មានន័យថា ត្រូវវិភាគអំពីប្រសិទ្ធភាពនៃការចំណាយ(Cost-Effectiveness Analysis) ដោយត្រូវពិនិត្យទៅលើ**តម្លៃចំណាយមួយឯកតា** នៃជម្រើសមួយធៀបទៅនឹង

ជម្រើសមួយទៀត តើជម្រើសមួយណាអស់តិចជាង៕ ពេលនោះ នឹងអាចរកឃើញនូវជម្រើសមួយដ៏ប្រសើរបំផុត ។

<u>ឧទាហរណ៍</u> រដ្ឋាភិបាលមានបំណងកាត់បន្ថយចំនួនគ្រោះថ្នាក់ចរាចរណ៍ និងអត្រាអ្នកស្លាប់ដែលបណ្តាលមកពីអ្នកបើកបរដោយម៉ូតូ ។ បើតាមស្ថិតិប្រចាំខែបានបង្ហាញថាគ្រោះថ្នាក់ចរាចរណ៍មានចំនួន១០០០ករណី ដែលក្នុងនោះ អត្រាអ្នកស្លាប់មានចំនួន ៣០% ។

ដើម្បីកាត់បន្ថយអត្រាស្លាប់ដោយសារគ្រោះថ្នាក់ដល់ជីវិត **មានជម្រើស៣** ដែលត្រូវលើកយកមកសិក្សាគឺ៖

ទី១-តម្រូវឲ្យអ្នកបើកបរម៉ូតូទាំងអស់ពាក់មួកសុវត្ថិភាព ហើយមួកសុវត្ថិភាពមួយតម្លៃ ២៥,០០០រៀល រីឯអ្នកបើកបរមានចំនួនដល់ទៅ ៥០០,០០០នាក់ ។

ទី២-តម្រូវឲ្យរោងចក្របំពាក់សម្ភារៈសុវត្ថិភាពលើម៉ូតូការពារពេលមានគ្រោះថ្នាក់ ដោយក្នុងម៉ូតូមួយគ្រឿងត្រូវចំណាយអស់ថវិកា ១៨,០០០ រៀល ។

ទី៣-រដ្ឋាភិបាលប្រើយុទ្ធនាការអប់រំនិងផ្សព្វផ្សាយដល់អ្នកបើកបរម៉ូតូទាំងអស់ ។ ក្នុងជម្រើសនេះត្រូវការថវិកាសរុបចំនួន ៦០០ លានរៀល ។

**ជាលទ្ធផល** នៃការអនុវត្តវិធានការទាំង៣ ខាងលើនេះ បង្ហាញថា ៖

- ជម្រើសទី១ ចំនួនគ្រោះថ្នាក់ចរាចរណ៍មិនថយចុះ គឺនៅ១០០០ ករណីដដែល ប៉ុន្តែ អត្រាអ្នកស្លាប់ថយចុះមកត្រឹម**១៧.៥%**
- ជម្រើសទី២ ចំនួនគ្រោះថ្នាក់ចរាចរណ៍ថយមកត្រឹម**៩០០**ករណី និងអត្រាអ្នកស្លាប់ថយចុះត្រឹម**២០%**
- ជម្រើសទី៣ ចំនួនគ្រោះថ្នាក់ចរាចរណ៍ថយចុះត្រឹម**៨០០** ករណី និងអត្រាអ្នកស្លាប់មិនថយចុះ គឺមានកម្រិត **៣០%** ដដែល

ផ្អែកតាមសម្មតិកម្មខាងលើ តើជម្រើសមួយណាដែលមានការចំណាយតិច និងទទួលបានប្រសិទ្ធភាពជាងគេ?

យើងអាចធ្វើការបកស្រាយនូវឧទាហរណ៍ខាងលើនេះ តាមជម្រើសពីរគឺ **ពេលមិនមានវិធានការ** និង**មានវិធានការ** ។ ប្រសិនបើពុំមានវិធានការ ចំនួនគ្រោះថ្នាក់ចរាចរណ៍គ្មានការប្រែប្រួលគឺនៅ១០០០ករណីដដែល រីឯ អត្រាអ្នកស្លាប់ក៏នៅ៣០% ដដែល ។ ដូច្នេះ យើងអាចគណនារកចំនួនអ្នកស្លាប់គឺ ១០០០ ករណី x ៣០% = ៣០០នាក់ ។

ផ្ទុយទៅវិញ **ពេលមានវិធានការ** យើងធ្វើការគណនានៅលើជម្រើសទាំងបីខាងលើ ដូចខាងក្រោម ៖

- ជម្រើសទី១ ចំនួនគ្រោះថ្នាក់ចរាចរណ៍មិនថយចុះ គឺនៅ**១០០០** ករណីដដែល ប៉ុន្តែ អត្រាអ្នកស្លាប់ថយចុះមកត្រឹម**១៧.៥%** ដូច្នេះ ចំនួនអ្នកស្លាប់គឺមាន ៖

☛ ១០០០ករណី x ១៧.៥% = ១៧៥នាក់

☛ ចំណាយថវិកា ២៥,០០០៛ x ៥០០,០០០នាក់ ដែលស្មើនឹង ១២,៥០០,០០០,០០០៛

- ប្រៀបធៀបនៅពេល**ពុំទាន់មានវិធានការ** គឺបានជួយជីវិតប្រជាពលរដ្ឋចំនួន ៣០០-១៧៥ =**១២៥នាក់** ។

ដូច្នេះ ថ្លៃចំណាយសម្រាប់**ជីវិតមនុស្សម្នាក់** គឺស្មើនឹង ១២,៥០០,០០០,០០០ ៖ ១២៥ = **១០០,០០០,០០០៛**

- ជម្រើសទី២ ចំនួនគ្រោះថ្នាក់ចរាចរណ៍ថយមកត្រឹម **៩០០**ករណី និងអត្រាអ្នកស្លាប់ថយចុះត្រឹម**២០%**

☛ ៩០០ករណី x ២០% = ១៨០នាក់

☛ ចំណាយថវិកាអស់ ១៨ ០០០៛ x ៥០០០០០នាក់ ស្មើនឹង ៩ ០០០ ០០០ ០០០៛

- បើសិនប្រៀបធៀបពេល**ពុំទាន់មានវិធានការ** គឺបានជួយជីវិតប្រជាពលរដ្ឋចំនួន៣០០-១៨០=**១២០**នាក់

ដូច្នេះ ថ្លៃចំណាយសម្រាប់**ជីវិតមនុស្សម្នាក់** គឺស្មើនឹង ៩,០០០,០០០,០០០ ៖ ១២០ = **៧៥,០០០,០០០៛**

- <u>ជម្រើសទី៣</u> ចំនួនគ្រោះថ្នាក់ចរាចរណ៍ថយចុះត្រឹម **៨០០** ករណី និងអត្រាអ្នកស្លាប់មិនថយចុះ គឺមានកម្រិត **៣០%** ដដែល

☛ ៨០០ករណី x ៣០% = ២៤០នាក់

☛ ចំណាយថវិកាអស់ ៦០០ ០០០ ០០០៛

- បើសិនប្រៀបធៀបពេល**ពុំទាន់មានវិធានការ** គឺបានជួយជីវិតប្រជាពលរដ្ឋចំនួន ៣០០-២៤០=**៦០**នាក់ ។

ដូច្នេះ ថ្លៃចំណាយសម្រាប់**ជីវិតមនុស្សម្នាក់** គឺស្មើនឹង ៦០០,០០០,០០០ ៖ ៦០ = <u>**១០,០០០,០០០៛**</u> ។

ក្នុងជម្រើសទាំង៣ខាងលើ យើងអាចធ្វើការសន្និដ្ឋានបានថា <u>**ជម្រើសទី៣**</u> គឺជាជម្រើសមានប្រសិទ្ធភាពជាងគេ ព្រោះអាចចំណាយតិច និងចំណេញច្រើន (Cost-Effectiveness) ។ ដូច្នេះ វិធានការនេះ ប្រសើរជាងគេដោយចំណាយថវិកាសម្រាប់ការពារគ្រោះថ្នាក់ជីវិត<u>***មនុស្សម្នាក់អស់ត្រឹមតែ ១០,០០០,០០០៛***</u>ប៉ុណ្ណោះ ។

## ជំហានទី៧៖ ដំណាក់កាលអនុវត្ត និង ត្រួតពិនិត្យការអនុវត្ត

## (Implementation and review)

ក្នុងដំណាក់កាលនេះ យើងត្រូវពិនិត្យថាបើយើងចង់តាក់តែងច្បាប់មួយ តើច្បាប់ហ្នឹងត្រូវអនុវត្តដូចម្តេច? ហើយក្នុងជំហានហ្នឹងយើងមានចំណុចមួយចំនួនដែលត្រូវគិតគូរ ។ **ទីមួយ** គួរតែពិចារណាលើការផ្តល់ព័ត៌មានទាក់ទង ថាតើត្រូវផ្សព្វផ្សាយច្បាប់ហ្នឹង ដើម្បីឲ្យបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋដូចម្តេច? **ទីពីរ** តើមានវិធានការដូចម្តេចខ្លះដើម្បីធ្វើការត្រួតពិនិត្យការអនុវត្ត? **ទីបី** តើច្បាប់ដែលយើងដាក់ទៅហ្នឹងគួរត្រូវបានពិនិត្យឡើងវិញដែរ ឬអត់?

តាមបទពិសោធន៍អនុវត្តនៅបណ្តាប្រទេសមួយចំនួនបង្ហាញថា បន្ទាប់ពីច្បាប់ចូលជាធរមានក្នុងរយៈពេល ពី៣ទៅ៥ឆ្នាំ គេត្រូវត្រួតពិនិត្យមើលឡើងវិញនូវស្ថានភាព និង កាលៈទេសៈជាក់ស្តែងក្នុងសង្គម ថាតើមានបញ្ហាអ្វីខ្លះដែលបានកើតឡើង ឬមួយមកពីបទប្បញ្ញត្តិ ឬមកពីអ្នកអនុវត្ត ។ល។ **ទីបួន** តើហេតុអ្វីបានជាច្បាប់នេះវាចាំបាច់? នោះគឺនៅពេលច្បាប់ត្រូវបានដាក់ឲ្យអនុវត្ត ប្រជាពលរដ្ឋ ឬអ្នកពាក់ព័ន្ធដឹងថា មានការផ្លាស់ប្តូរអ្វីមួយ ជាអាទិ៍ ការចំណាយថវិកាតិច ហើយថែមទាំងអាចកាត់បន្ថយនូវអត្រាស្លាប់ ដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍ ដូចមានក្នុងជម្រើសទី៣ (ទំព័រ ៣២) ខាងលើ ។

# សេចក្តីសន្និដ្ឋាន

ផ្អែកតាមអំណះអំណាង [10] របស់អ្នកឯកទេសលើកកម្ពស់ក្របខ័ណ្ឌច្បាប់នៃបណ្តាប្រទេសជាច្រើន ជាពិសេសប្រទេសសមាជិក OECD យើងសង្កេតឃើញថា RIA គឺជាឧបករណ៍មួយប្រកបដោយសក្តានុពលល្អប្រសើរ ដែលជួយដល់ដំណើរការកំណែទម្រង់នានា និងលើកកម្ពស់គុណភាពក្របខ័ណ្ឌច្បាប់ ។ មានសូចនាករនៃការប្រែប្រួលមួយចំនួនដែលបង្ហាញនូវភាពខុសគ្នារវាងដំណើរការធ្វើច្បាប់ ដោយពុំមាន RIA និងដំណើរការធ្វើច្បាប់ដោយមាន RIA ។

សូចនាករទាំងនោះមាន ៖

| <u>ពុំមាន RIA</u> | <u>មាន RIA</u> |
|---|---|
| ☛ ពុំមានការវិភាគមុនពេលបង្កើតច្បាប់/បទប្បញ្ញត្តិថ្មី ឬការកែប្រែណាមួយ លើច្បាប់/បទប្បញ្ញតិដែលមានស្រាប់<br>☛ អាចប្រើវិធីសាស្ត្រ «Copy-Paste» ក្នុងការបង្កើតច្បាប់/ បទប្បញ្ញត្តិ<br>☛បើមានការគណនាអំពីថ្លៃដែលត្រូវចំណាយ(Costs) និងផលប្រយោជន៍ | ☛ មានការវិភាគមុនពេលបង្កើតច្បាប់ /បទប្បញ្ញត្តិថ្មី ឬធ្វើការកែប្រែណាមួយលើច្បាប់/បទប្បញ្ញត្តិដែលមានស្រាប់<br>☛ ផ្តល់ការវិភាគថ្លៃដែលត្រូវចំណាយ(Costs) និងផលប្រយោជន៍ (Benefits) គ្រប់ ជ្រុង |

[10] យោងតាមបទបង្ហាញនានាដែលបកស្រាយដោយអ្នកជំនាញនានាក្នុងសន្និសីទអន្តរជាតិស្តីពីការកែទម្រង់ច្បាប់/បទប្បញ្ញត្តិ: ពីការិយាល័យធិបតេយ្យ ឆ្ពោះទៅរកច្បាប់/បទប្បញ្ញត្តិល្អប្រសើរ » ធ្វើនៅប្រទេសអាល្លឺម៉ង់ពីថ្ងៃទី ៩-១១ ខែធ្នូ ឆ្នាំ២០០៧ ។

| | |
|---|---|
| (Benefits) ក៏មានតែសម្រាប់រយៈពេលខ្លីប៉ុណ្ណោះ<br>☛ការប្រឹក្សាយោបល់ត្រូវបានធ្វើឡើងតែក្នុងរូបភាពដាក់ឲ្យយល់ដឹងជាទូទៅ (Socialization) **នៅក្រោយពេល** ដែលច្បាប់/បទប្បញ្ញត្តិថ្មីនោះត្រូវបានបង្កើត ឬការកែប្រែណាមួយលើច្បាប់/ បទប្បញ្ញត្តិដែលមានស្រាប់ត្រូវបានធ្វើ រួចប៉ុណ្ណោះ | ជ្រោយរបស់ជម្រើស ដំណោះស្រាយនីមួយៗ<br>☛ មានឧបករណ៍ប្រកបដោយលក្ខណៈជាប្រព័ន្ធ និងប្រកបដោយនិយាមត្រឹមត្រូវ<br>☛ ការប្រឹក្សាយោបល់ធ្វើឡើងនៅគ្រប់ដំណាក់កាល |

មានសំណួរពិភាក្សាមួយត្រូវបានចោទឡើង ថាតើប្រទេសនីមួយៗ គួរតែបន្តការវិនិយោគបន្ថែមលើការពង្រីកការអនុវត្ត RIA ឬយ៉ាងណា ផ្អែកតាមបទពិសោធន៍នៃ ការអនុវត្តកន្លងមក?[11]

មានចម្លើយមួយក្នុងចំណោមចម្លើយសមស្របជាច្រើន ត្រូវបានកត់សម្គាល់ ។ ចម្លើយនោះគឺថា « យើងពុំគួរនាំគ្នា ផ្តោតការនិយាយតែនៅលើការពង្រឹងគុណភាព និងពង្រីក ការអនុវត្ត RIA ប៉ុណ្ណោះទេ អ្វីដែលសំខាន់ជាងនេះគឺយើងគួរ នាំគ្នាមើលថា តើមានការទទួលយកកម្រិតណាពីសំណាក់ អ្នកនយោបាយ ឬអ្នកដែលមានអំណាចធ្វើការសម្រេចចិត្ត ? ព្រោះថា វាគ្មានប្រយោជន៍អ្វីទាល់តែសោះ

[11] «សន្និសីទអន្តរជាតិស្តីពីការកែទម្រង់ច្បាប់បទប្បញ្ញត្តិ៖ ពីការិយាល័យធិបតេយ្យឆ្ពោះទៅរកច្បាប់/បទប្បញ្ញត្តិល្អប្រសើរ» ធ្វើនៅប្រទេសអាល្លឺម៉ង់ពីថ្ងៃទី ៥-១១ ខែធ្នូ ឆ្នាំ២០០៧ ។

ចំពោះ RIA ដែល មានគុណភាពល្អបំផុតមួយ ប៉ុន្តែ មិនត្រូវបានទទួលយកទៅ ពិចារណានោះ» ។ ដូចនេះ សរុបមក ចម្លើយខ្លីមួយត្រូវបាន សន្មត់យកគឺ *«យើងគួរបន្តការវិនិយោគចំពោះRIA ប៉ុន្តែ គួរធ្វើ ការវិនិយោគនោះប្រកបដោយភាពឆ្លាតវៃ និងយកចិត្តទុកដាក់ ទាំងលើផ្នែកបរិមាណ និងគុណភាព ហើយជាមួយគ្នានោះ ត្រូវជំរុញឲ្យមានការចូលរួម និងការទទួលយកផងដែរ»* ។

ដូច្នេះហើយ ក្រៅពីការយល់ដឹងខ្លឹមសារពិស្តារផ្នែកទ្រឹស្តី ការអនុវត្តRIA ឲ្យក្លាយទៅជាវិធីសាស្ត្រផ្លូវការមួយរបស់ស្ថាប័ន (Institutionlized) គេត្រូវការចាំបាច់នូវកត្តាសំខាន់ៗមួយចំនួនទៀត មានជាអាទិ៍ :

១- ការគាំទ្រពីសំណាក់អ្នកធ្វើការសម្រេចចិត្តសំខាន់ៗ

២- យន្តការសម្របសម្រួលមានលក្ខណ:ស៊ីជម្រៅនិងប្រកបដោយប្រសិទ្ធភាព

៣- ព័ត៌មាន-ទិន្នន័យ សម្រាប់គណនារកផលប៉ះពាល់ (Costs) និងផលប្រយោជន៍(Benefits)

៤- ការចូលរួមសមស្របពីសំណាក់ដៃគូក្នុងវិស័យឯកជន

ទោះជាយ៉ាងណាក៏ដោយ សូមចងចាំថា RIA ពុំមែនជាឧបករណ៍សម្រាប់ ***ជំនួសទាំងស្រុងនូវការសម្រេចចិត្តណាមួយ*** ក្នុងការបង្កើតច្បាប់/បទប្បញ្ញត្តិថ្មី ឬការកែប្រែណាមួយលើច្បាប់/បទប្បញ្ញត្តិ ដែលមានស្រាប់នោះទេ វាគ្រាន់តែជាឧបករណ៍ណែនាំដ៏ល្អបំផុតមួយ សម្រាប់ជួយធ្វើឲ្យប្រសើរឡើងនូវការសម្រេចចិត្តផ្នែកនយោបាយ និងរដ្ឋបាល ខណៈដែលនៅពេលជាមួយគ្នានោះ វាអាចជួយធានានូវតម្លៃនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ និងគណនេយ្យភាពចំពោះសាធារណៈជន និង ជួយទ្រទ្រង់នូវផលប្រយោជន៍ពិតប្រាកដរបស់ផ្នែកឯកជន ។

# ករណីសិក្សា

យើងនឹងលើកយកករណីសិក្សាជាក់ស្តែងមួយ មកបង្ហាញដើម្បីផ្តល់នូវរូបភាពរួមរបស់ RIA នៅក្នុងបរិបទនៃការអនុវត្ត ។ ករណីសិក្សានេះនឹងបកស្រាយអំពីការធ្វើ RIA លើវិធានការតតិយុត្តមួយ ដែលរដ្ឋាភិបាលប្រទេសឥណ្ឌូនេស៊ុគ្រោងនឹងធ្វើការកែសម្រួល និងបន្តឹងការអនុវត្តជាកំហិតនូវបទប្បញ្ញត្តិច្បាប់ស្តីអំពី «ស្តង់ដារគ្រាប់កាកាវជាតិឥណ្ឌូនេស៊ុ ដែលបង្កើតនៅឆ្នាំ ២០០២ (Indonesian National Standard on Cocoa Beans—23-23/01/2002)។

ករណីសិក្សានេះ នឹងបង្ហាញអំពីរចនាសម្ព័ន្ធ និងទម្រង់នៃការរៀបចំព័ត៌មានក្នុងជំហាននីមួយៗរបស់ RIA។គួរកត់សម្គាល់ថា រាល់ព័ត៌មាន និងតួលេខទាំងអស់ដែល ប្រើក្នុងករណីសិក្សានេះ សុទ្ធសឹងបានមកតាមរយៈការប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធចាំបាច់នានា និងការស្រាវជ្រាវច្បាស់លាស់ ទោះបីជាឯកសារលំអិតនៃការប្រឹក្សាយោបល់ និងការស្រាវជ្រាវទាំងនេះ ពុំត្រូវបានដាក់ភ្ជាប់មកជាមួយក៏ដោយ។ ដូច្នេះតោងយើងចងចាំថា ព័ត៌មានទាំងឡាយដែលជាអំណះអំណាងនៅក្នុងការធ្វើRIA ពុំមែន ឬពុំគួរជាទស្សនៈ ឬការសន្មត់ផ្ទាល់ខ្លួនរបស់អ្នកធ្វើរបាយការណ៍RIA ឡើយ។

ខាងក្រោមនេះ គឺជាខ្លឹមសារ និងទម្រង់នៃរបាយការណ៍ RIA៖

**«ការវាយតម្លៃផលប៉ះពាល់នៃច្បាប់/បទប្បញ្ញត្តិស្តីអំពីគ្រាប់កាកាវ»**

**I-ការកំណត់បញ្ហា** (Identify Problem)

**១.ចំពោះកសិករ:** ភាគច្រើននៃផលិតផលគ្រាប់កាកាវដែលកសិករផលិត(ជាង៩០%) គឺជាផលិតផលដែលមិនបានធ្វើការកែច្នៃ (Not Fermented) ហើយដើមកាកាវទាំងនោះ (៥៥%)ជាដើមចាស់ៗ(ជា ង២៥ឆ្នាំ)។ ម្យ៉ាងទៀត ដំណាំនេះក៏ទទួលរងការបំផ្លិចបំផ្លាញពីសត្វល្អិតស៊ីគ្រាប់កាកាវ រីឯទុនរបស់កសិករក៏មានតិច។

**២.ចំពោះធុរជន:** ធុរជនពុំផ្តល់កម្រិតថ្លៃខុសគ្នាខ្លាំងប៉ុន្មាន រវាងផលិតផលគ្រាប់កាកាវគុណភាពខ្ពស់ និងគុណ-ភាពទាប ឬផលិផលដែលបានកែច្នៃ (Fermented) និងមិនបានកែច្នៃ(Not Fermented)។

**៣.ចំពោះអ្នកនាំចេញ:** ជាទូទៅអ្នកនាំចេញចូលចិត្តនាំចេញផលិតផលគុណភាពទាប និង ឬ មិនបានកែច្នៃ ដោយសារគេអាចទិញបានក្នុងតម្លៃថោក ។ ប៉ុន្តែថ្លៃលក់ផលិតផលបែបនេះចេញទៅក្រៅប្រទេសក៏បានថោកដែរ ។ នៅឆ្នាំ ២០០៥ កម្រិតខុសគ្នានៃថ្លៃគ្រាប់កាកាវរបស់ឥណ្ឌូនេស៊ី

និងគ្រាប់កាកាវរបស់ប្រទេសកូឌីវ៉រ និងហ្គាណា គឺ២០០ដុល្លាអាមេរិកក្នុងមួយតោន (គ្រាប់កាកាវឥណ្ឌូនេស៊ីថោកជាង) ។ លើសពីនេះទៀត តាម ក្រឹត្យក្រមនៃការនាំចេញ តម្រូវឲ្យអ្នកនាំចេញត្រូវចំណាយបន្ថែម ៩ដុល្លាអាមេរិក ក្នុងមួយ តោនសម្រាប់ការកែច្នៃចាំបាច់ (ឧ.ការសម្លាប់មេរោគ...)។

**៤.ចំពោះរដ្ឋាភិបាលៈ** បទដ្ឋានស្តីពីស្តង់ដារគ្រាប់ កាកាវជាតិឥណ្ឌូនេស៊ី អនុញ្ញាតិឲ្យអ្នក នាំចេញធ្វើការនាំចេញនូវផលិតផលគ្រាប់កាកាវដែលឋិតក្នុងប្រភេទទី៣ (ប្រភេទគុណភាពទាប និងក្នុងករណីខ្លះមិនបានកែច្នៃ)។ រីឯការត្រួតពិនិត្យការអនុវត្តបទដ្ឋានច្បាប់ នេះក៏ទន់ខ្សោយ និងពុំមានប្រសិទ្ធភាពទៀតផង។

**៥.ចំពោះសហគ្រាសកែច្នៃៈ** អាករលើតម្លៃបន្ថែមចំនួន ១០% ត្រូវបានដាក់លើរាល់ការទិញ ផលិតផលគ្រាប់កាកាវសម្រាប់ការកែច្នៃក្នុងស្រុក ហើយមិនមែនសម្រាប់នាំចេញ។

II-**<u>ការកំណត់គោលបំណង</u>** (Define Objective)

៦.ឲ្យកសិករយល់ព្រមកែច្នៃ (Ferment) ផលិតផលគ្រាប់ កាកាវរបស់ពួកគេ និងប្រើប្រាស់វិធី សាស្ត្រថែរក្សាត្រឹមត្រូវក្រោយពេលប្រមូលផលរួច។

៧.ឲ្យកសិកររួមជាមួយរដ្ឋាភិបាល ធ្វើយ៉ាងណាខិតខំដាំជំនួសដើមកាកាវចាស់ៗនូវដើមថ្មីៗ។

៨.ឲ្យរដ្ឋាភិបាលរួមជាមួយសមាគមន៍ពាណិជ្ជកម្ម ធ្វើយ៉ាងណាជួយដោះស្រាយបញ្ហាសត្វបំផ្លាញគ្រាប់កាកាវ។

III-**<u>ការកំណត់ជម្រើសដំណោះស្រាយ</u>**(Identify Options)

៩.មានជម្រើសដំណោះស្រាយចំនួន០២ត្រូវបានកំណត់ និងពិចារណា៖

**-ជម្រើសទី១** មិនចាត់វិធានការណ៍ថ្មីអ្វីទាំងអស់ដោយនៅបន្តប្រើលក្ខខណ្ឌបច្ចុប្បន្ន និងសង្ឃឹមថាបញ្ហានឹងត្រូវបានដោះស្រាយដោយឯកឯងក្នុង បរិយាកាសទីផ្សារ។

- **ជម្រើសទី២** ធ្វើការកែសម្រួល និងរឹតបន្តឹងការអនុវត្តជាកំហិតនូវបទប្បញ្ញត្តិច្បាប់ស្ដីអំពី «ស្តង់ដារគ្រាប់កាកាវជាតិឥណ្ឌូនេស៊ីដែលបង្កើតនៅឆ្នាំ២០០២ ដើម្បីឲ្យមានសង្គតិភាពក្នុងការកំណត់លក្ខណៈរបស់គ្រាប់កាកាវ តាមរយៈការពង្រឹងការអនុវត្តបញ្ញត្តិនានា ពាក់ព័ន្ធនឹងលក្ខខណ្ឌនៃគុណភាពលក្ខខណ្ឌពិសេសនានា និងការត្រួតពិនិត្យគុណភាព ប្រកបដោយប្រសិទ្ធភាព ទាំងសម្រាប់គ្រាប់កាកាវដែលនាំចេញ និងគ្រាប់ដែលចែកចាយសម្រាប់ទីផ្សារក្នុងស្រុក។

## IV-ការវិភាគលើផលប៉ះពាល់ធៀបនឹងផលប្រយោជន៍នៃជម្រើសនីមួយៗ (Impact Cost/Benefit Analysis)

### ១០.ផលប៉ះពាល់(Costs):

| ជម្រើស | ល.រ | ផលប៉ះពាល់ | | |
|---|---|---|---|---|
| | | របៀបគុណភាព (Qualitative) | របៀបបរិមាណ (Quantitative) (លានរៀល) | កំណត់សម្គាល់ កំណត់សម្គាល់ (Note) |
| ១ | - | គ្មាន(បន្ថែមថ្មី) | - | - |
| ២ | ១ | ថ្លៃកែច្នៃគ្រាប់កាកាវ (Fermentation) | ៥០៩.៤០០ | (ថ្លៃកែច្នៃតាមលក្ខខណ្ឌ តម្រូវx បរិមាណ ផលិតផល ប្រចាំឆ្នាំ)+ (ថ្លៃប្រាក់ឈ្នួល ពលកម្មx បរិមាណ ផលិត ផលប្រចាំឆ្នាំ)+(ថ្លៃរំលោះx បរិមាណផលិតផលប្រចាំឆ្នាំ)+ (ថ្លៃការប្រាក់លើប្រាក់កម្ចីx បរិមាណ ផលិតផលប្រចាំឆ្នាំ) →(៥០០រៀល/គ x ៦០០.០០០គ)+ (២៨៥រៀល/គx ៦០០.០០០គ)+ (១៣រៀល/គx ៦០០.០០០គ) |
| | ២ | ថ្លៃកែសម្រួលបទប្បញ្ញត្តិស្តីពី-ស្តង់ដារគ្រាប់ កាកាវជាតិកម្ពុជានេស៊ុ- និងផ្សព្វផ្សាយ | ៤០០ | (ថ្លៃកែសម្រួល+ថ្លៃផ្សព្វផ្សាយព័ត៌មាន) →(២៥០.០០០.០០០រៀល+ ២៥០.០០០.០០០ រៀល) |
| | | សរុប | ៥០៩.៨០០ | |

## ១១.ផលប្រយោជន៍(Benefits):

| ជម្រើស | ល.រ | ផលប្រយោជន៍ | | |
|---|---|---|---|---|
| | | បែបគុណភាព | បែបបរិមាណ | កំណត់សម្គាល់ |
| ២ | ១ | កំណើនថ្លៃលក់ផលិតផល | ២.៦៦៨.៤២៦ | (ការប្រែប្រួលនៃថ្លៃលក់ ផលិតផលពីកសិករ+ពីធុរជន +ពីអ្នក នាំចេញ)→ (៨៧២.៥៦៨,៦១២លាន+ ១.០៨៨.៥៦២,២២៧លាន+ ៧០៧.២៩៥,០៥០លាន) |
| | ២ | គុណភាពគ្រាប់កាកាវប្រសើរឡើង | ពុំអាចគណនាជាតួលេខ | ពុំអាចគណនាជាតួលេខ |
| | ៣ | រួចផុតពីបន្ទុកចំណាយបន្ថែមពេលនាំផលិតផលគ្រាប់កាកាវ ចេញក្រៅប្រទេស | ៤.៩២៤ | ((ចំណាយបន្ថែមក្នុងបរិមាណ គ្រាប់កាកាវនាំចេញក្នុង១តោន× ឯកតាប្រាក់រៀលក្នុង១ដុល្លារអាមេរិក)× បរិមាណនាំចេញទៅអាមេរិក) → (៨ដុល្លាអាមេរិក/ត× ៥.៧១៨,៦រៀល)×១០៧.៦៣០ត |
| | ៤ | មានវត្ថុធាតុដើមជាគ្រាប់កាកាវ កែច្នៃ គ្រប់គ្រាន់សម្រាប់ ផ្គត់ផ្គង់ និងមានតម្លៃថោក សមរម្យសម្រាប់ការប្រើប្រាស់ក្នុងស្រុកដោយមិនបាច់នាំ ចូលពីក្រៅប្រទេស | ៦៩.០០០ | ((ថ្លៃនាំចូលគ្រាប់កាកាវកែច្នៃ +ពន្ធនាំចូល៥%)-ថ្លៃគ្រាប់កាកាវកែច្នៃ ក្នុងស្រុក)×បរិមាណគ្រាប់កាកាវ ដែលត្រូវការ→((១៦.០០០រៀល/ត+ ៨០០រៀល)-១៤.៥០០រៀល)× ៣០.០០០ត → ចំនួននេះ ពុំទាន់គិតបញ្ចូលពន្ធលើប្រាក់ចំណេញ និងពន្ធលើតម្លៃ បន្ថែមទៀត |

| | | | |
|---|---|---|---|
| ៥ | កំណើនការប្រើប្រាស់សេវាសហគ្រាស កែច្នៃក្នុងស្រុក | ៧៧២ | (ការប្រែប្រួលនៃអត្រាប្រើប្រាស់= អត្រាក្នុងករណីអនុវត្តជម្រើសទី២- អត្រាក្នុងករណីមិនអនុវត្តជម្រើសទី២) x((ថ្លៃជាមធ្យមនៃប័ណ្ណនាំចេញ)-ថ្លៃគ្រាប់កាកាវ)→(១៨៥.០០០រៀល-១១៥.០០០រៀល)x១១.១៨៩រៀល |
| ៦ | ការសន្សំបានពីមិនប្តូរប្រាក់ បរទេស ក្នុងចរន្តនៃការនាំ ចេញ-ចូល | ពុំអាចគណនា ជាតួលេខ | ពុំអាចគណនាជាតួលេខ |
| ៧ | កំណើនឱកាសការងារ | ពុំអាចគណនា ជាតួលេខ | ពុំអាចគណនាជាតួលេខ |
| | សរុប | ២.៧៣៩.៣៧៦ | |

## V-ការប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធ

(Consultation with Stakeholders)

១២.ក្រុមការងារវាយតម្លៃផលប៉ះពាល់នៃច្បាប់ បានធ្វើការប្រឹក្សាយោបល់ជាសាធារណៈ ជាមួយភាគីពាក់ព័ន្ធជាច្រើននៅតំបន់ដាំកាកាវ Medan Makassar និង Jakarta រួមទាំងអ្នកនាំចេញគ្រាប់កាកាវ, សមាគមពាណិជ្ជកម្ម សហគមន៍ កាកាវភូមិ, អ្នកផ្តល់សេវាដាំដុះ, អង្គភាពឧស្សាហកម្ម និង ធុរកិច្ចខេត្ត, សាកលវិទ្យាល័យមួយចំនួន, NGOs, និងកសិករ ផងដែរ។

## VI-ការកំណត់ជម្រើសដំណោះស្រាយ

(Choose Recommended Option)

១៣.ឆ្លងតាមរយៈ ការវាយតម្លៃលើផលប៉ះពាល់ធៀបនឹងផលប្រយោជន៍នៃជម្រើសនីមួយៗខាងលើឃើញថា ជម្រើសដែលរដ្ឋាភិបាលធ្វើការកែសម្រួល និង រឹតបន្តឹងដាក់ហិតនូវការ អនុវត្តបទប្បញ្ញត្តិស្តីពី «**ស្តង់ដាគ្រាប់កាការជាតិឥណ្ឌានេស៊ី ដែលបង្កើតនៅឆ្នាំ២០០២**» និងការធានាឲ្យមានវិធានការត្រួត ពិនិត្យគុណភាពគ្រាប់កាការប្រកបដោយប្រសិទ្ធភាព ទាំងសម្រាប់គ្រាប់កាការនាំចេញ និង គ្រាប់កាការចែកចាយនៅទីផ្សារក្នុងស្រុក គឺជាជម្រើសដែលនឹងអាចនាំនូវផល - ប្រយោជន៍បន្ថែម(Additional Benefits) ដែលមានចំនួនច្រើនជាងផលប៉ះពាល់(Costs) ដែលអាចមាន។

## VII-ការអនុវត្ត និងការពិនិត្យឡើងវិញ(Implementation and Review)

១៤.ដើម្បីអនុវត្តជម្រើសដំណោះស្រាយ ដែលរួមមានការកែសម្រួលការអនុវត្តបទប្បញ្ញត្តិស្តីពី ស្តង់ដារគ្រាប់កាការជាតិឥណ្ឌានេស៊ី និងការពង្រឹងការអនុវត្តតាមរយៈការត្រួតពិនិត្យតឹងរ៉ឹង៖

- ជាដំបូងត្រូវមានយុទ្ធនាការសាធារណៈមួយ ដើម្បីជួយឲ្យបណ្តាប្រតិបត្តិករពាណិជ្ជកម្មដែលពាក់ព័ន្ធ (កសិករ

ធុរជន អ្នកនាំចេញ និងគ្រឹះស្ថានឧស្សាហកម្មកែច្នៃក្នុងស្រុក) យល់ពីការកែសម្រួលនេះ និងអាចសម្របខ្លួនអនុវត្តលក្ខខណ្ឌ នៃបទប្បញ្ញត្តិកែសម្រួលថ្មីនេះបាន។

- ត្រូវមានរយៈពេលអន្តរកាលមួយ ដើម្បីដោះស្រាយ «បញ្ហាខុសទម្លាប់វប្បធម៌នៃការអនុវត្ត (Culture Shocks)» ដែលអាចកើតឡើងដោយសារការអនុវត្តជម្រើស ដំណោះស្រាយទី២នេះ។ បទប្បញ្ញត្តិកែសម្រួលនេះនឹង ត្រូវការពេលវេលាប្រមាណ២-៣ឆ្នាំដើម្បី អាចអនុវត្តបានពេញលេញ ហើយក្នុងពេលជាមួយគ្នានោះដែរ រដ្ឋាភិបាលនឹងចេញនូវគោលនយោបាយ ដែលទប់ស្កាត់ការនាំចេញគ្រាប់កាកាវគុណភាពទាប។

-ត្រូវមានបរិក្ខាជួយសម្រួល និងហេដ្ឋារចនាសម្ព័ន្ធ គាំទ្រនានា (ដូចជាស្ថាប័នធ្វើតេស្តគុណភាព ស្ថាប័នប្រមូលផ្តុំប៉ាន់គំរូ ការដាក់ទណ្ឌកម្មតឹងរ៉ឹង ការសម្របសម្រួលច្បាស់លាស់រវាងភាគីពាក់ព័ន្ធទាំងអស់។ល។) ។

-ត្រូវមានកម្មវិធីចាំបាច់នានា ដើម្បីធ្វើឲ្យប្រសើរឡើងនូវគុណភាពគ្រាប់កាកាវ ជំរុញការដាំជំនួសដើមកាកាវចាស់ដោយដើមថ្មីៗ ជំរុញការកំចាត់សត្វល្អិតស៊ីគ្រាប់កាកាវ និង ផ្តល់ជំនួយប្រឹក្សាពីអ្នកឯកទេសខាងកសិកម្មអតិផល។

-ត្រូវមានវេទិកាប្រកបដោយប្រសិទ្ធភាពមួយដើម្បីសម្របសម្រួល រាល់សកម្មភាព ទាំងនេះ។

## Regulatory Impact Assessment[12]




[12] ឯកសារបណ្តុះបណ្តាល របស់ បណ្ឌិត Hari Setianto អ្នកជំនាញផ្នែកវាយតម្លៃ ផលប៉ះពាល់នៃច្បាប់ ប្រទេសឥណ្ឌូនេស៊ី ។

# មេរៀនសង្ខេប
# អំពីការអនុវត្ត RIA នៅក្នុងប្រទេសឥណ្ឌូណេស៊ី

## ១-កំណត់បញ្ហា

-តើអ្វីជាបញ្ហាដែលយើងចង់ដោះស្រាយ?តើបញ្ហានោះសំខាន់កម្រិតណា?

-ហេតុអ្វីបានជាចាំបាច់ត្រូវមានសកម្មភាពរបស់ រដ្ឋាភិបាល ដើម្បីកែតម្រូវបញ្ហានេះ?

-តើមានច្បាប់/បទប្បញ្ញត្តិជាធរមាន ទាក់ទងនឹងបញ្ហានោះរឺទេ?

-តើហេតុអ្វីបានជាបទប្បញ្ញត្តិដែលកំពុងនៅជាធរមានទាំងនោះ មិនអាចដោះស្រាយបានសមស្របនូវបញ្ហាដែលយើងចង់ដោះស្រាយនោះ?

-តើអ្នកដែលពាក់ព័ន្ធទាំងអស់ យល់យ៉ាងណាចំពោះបញ្ហា?

## ២-កំណត់គោលដៅនៃសកម្មភាពរបស់រដ្ឋាភិបាល

-តើអ្វីជាគោលបំណង លទ្ធផល គោលដៅរឺជាទិសដៅនៃសកម្មភាពរបស់រដ្ឋាភិបាល?

-តើសកម្មភាពរបស់រដ្ឋាភិបាលនឹងអាចកែតម្រូវបញ្ហានេះទាំងមូល រឺត្រឹមតែផ្នែកណាមួយនៃបញ្ហា?

**៣-អំណាត់ជម្រើស**

-តើមានជម្រើសដំណោះស្រាយអ្វីខ្លះ ដែលអាចដោះស្រាយបញ្ហានេះបាន (អាចជួយសម្រេចនូវគោលដៅរបស់រដ្ឋាភិបាល)?

-បង្ហាញថាច្បាប់/បទ ប្បញ្ញត្តិថ្មី រឺ ការកែសម្រួលបទប្បញ្ញត្តិដែលមានស្រាប់នឹងអាចជួយដោះស្រាយបញ្ហានេះបាន

-ពិចារណាលើជម្រើសនានាក្រៅពីច្បាប់/បទប្បញ្ញត្តិ (ជម្រើសមិនមែនបញ្ញត្តិកម្ម Non-regulatory option) និងជម្រើសជាច្បាប់/បទប្បញ្ញត្តិ ប៉ុន្តែក្នុងទម្រង់ផ្សេងៗពីគ្នា (ជម្រើសបញ្ញត្តិកម្ម Regulatory option)

-គោងកុំភ្លេចពិចារណាលើជម្រើស«មិនធ្វើអ្វីសោះ (Doing-nothing option) »ជាជម្រើសដំណោះស្រាយមួយ។ តើបញ្ហានឹងអាចត្រូវបានកែតម្រូវវិញ ដោយសកម្មភាព «ឯកជន » របស់អ្នកដែលពាក់ព័ន្ធដែរ រឺ ទេ?

-តើអ្វីខ្លះជាហានិភ័យនៃការទុកបញ្ហាឲ្យនៅស្ថានភាពដដែល? តើហានិភ័យទាំងនោះមានវិសាលភាពប៉ុណ្ណា?

**៤-ការវិភាគផលប៉ះពាល់**

-តើអ្វីខ្លះជាការចំណាយផលចំណេញនិងផលប៉ះ ពាល់នៃជម្រើសនីមួយៗ?

-តើជម្រើស នីមួយៗនឹងមានការចំណាយ/ផលចំណេញ ដូចអ្វីដែលបានរំពឹងទុកដែរ រឺទេ? តើមានផលវិបាកអ្វីខ្លះ ដែលមិនបានរំពឹងទុកជាមុន?

-បង្ហាញពីផលប៉ះពាល់ផ្ទាល់ និងប្រយោលទៅលើ បរិស្ថានរដ្ឋាភិបាល ពាណិជ្ជកម្ម និយោជិត អ្នកប្រើប្រាស់ និងសមាគមទាំងមូល។

-បង្ហាញពីផលប៉ះពាល់លើការអភិវឌ្ឍប្រកបដោយ ចីរភាព និងថ្លឹងថ្លែង រវាងផលចំណេញខាងសង្គម និង សេដ្ឋកិច្ច

-កម្រិតនៃការវិភាគត្រូវតែសមមូលទៅនឹងសារសំខាន់នៃបញ្ហាដែលយើងចង់ដោះស្រាយ។

**<u>៥-ការពិគ្រោះយោបល់ជាមួយអ្នកដែលពាក់ព័ន្ធ</u>**

-តើអ្នកណាខ្លះដែលត្រូវបានប្រឹក្សាយោបល់? តើការប្រឹក្សាយោបល់នោះត្រូវបានធ្វើ ឡើងដោយរបៀបណា?

-តើអ្នកដែលត្រូវបានប្រឹក្សាយោបល់នោះ មានមតិយោបល់អ្វីខ្លះ? តើមានមតិយោបល់ ជំទាស់ដែរ រឺទេ?

-តើមតិយោបល់របស់ពួកគេមានឥទ្ធិពលរបៀបណាទៅលើលទ្ធផល (ច្បាប់/ បទប្បញ្ញត្តិ)?

-ការពិគ្រោះយោបល់អាចនឹងត្រូវបានអនុវត្តនៅគ្រប់ជំហាននីមួយៗនៃដំណើរការ RIA ៖

*ដើម្បីប្រមូលមតិយោបល់ និងការយល់ឃើញរបស់អ្នកដែលពាក់ព័ន្ធអំពីបញ្ហា

*ដើម្បីទទួលបានមតិយោបល់អំពីជម្រើសដំណោះស្រាយដែលអាចមាន

*ដើម្បីទទួលបានទឡ្ហីករបន្ថែម អំពីការចំណាយ និងផលចំណេញនានា ដែលត្រូវបានកំណត់រួចហើយ

*ដើម្បីទទួលបាននូវមតិត្រឡប់អំពីភាពអាចអនុវត្តបាននៃជម្រើសនីមួយៗ

**៦-សំយោគ និងជម្រើសអនុសាសន៍**

-តើជម្រើសមួយណាដែលសមស្របជាងគេ?

-ហេតុអ្វីបានជាជម្រើសមួយនេះត្រូវបានទទួលយក ហើយជម្រើសផ្សេងៗត្រូវបាន បដិសេធ?

**៧-ការអនុវត្ត និងការពិនិត្យឡើងវិញ**

- តើជម្រើសដែលត្រូវបានទទួលយកនោះនឹងត្រូវអនុវត្តតាមរបៀបណា?

-តើជម្រើសដែលត្រូវបានទទួលយកនោះច្បាស់លាស់ មានសង្គតភាព អាចយល់បាន និងងាយប្រើប្រាស់ដែរ រឺទេ?

-តើវិធីសាស្ត្រ និងការផ្សព្វផ្សាយបែបណានឹងត្រូវយកមកប្រើ ដើម្បីផ្តល់ព័ត៌មានទៅមជ្ឈដ្ឋានសាធារណៈអំពី លក្ខខណ្ឌតម្រូវនៃច្បាប់/បទប្បញ្ញត្តិដែលត្រូវបានបង្កើតថ្មី រឺ នៃ

ច្បាប់/បទប្បញ្ញត្តិដែលត្រូវបានការកែប្រែថ្មី(ការផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់)?

-តើប្រសិទ្ធិភាពនៃច្បាប់/បទប្បបញ្ញត្តិដែលត្រូវបានបង្កើតថ្មី រឺច្បាប់/បទប្បញ្ញត្តិដែលត្រូវបានការកែប្រែថ្មី នឹងត្រូវបានវាយតម្លៃដោយរបៀបណា? តើមានយន្តការអ្វីខ្លះ ដើម្បីធានាការអនុវត្តនូវច្បាប់/បទប្បបញ្ញត្តិដែលត្រូវបានបង្កើតថ្មី រឺច្បាប់/បទប្បញ្ញត្តិ ដែលត្រូវបានការកែប្រែថ្មី?

-តើច្បាប់/បទប្បបញ្ញត្តិដែលត្រូវបានបង្កើតថ្មី រឺច្បាប់/បទប្បញ្ញត្តិដែលត្រូវបានការកែប្រែថ្មីនឹងត្រូវបានពិនិត្យឡើងវិញដោយរបៀបណា?តើមានបញ្ញត្តិណាមួយនៅក្នុងច្បាប់/បទប្បបញ្ញត្តិដែលត្រូវបានបង្កើតថ្មី រឺច្បាប់/បទប្បញ្ញត្តិដែលត្រូវបានការកែប្រែថ្មី ចែងអំពីការពិនិត្យឡើងវិញ រឺការដាក់ និរាករណ៍បន្ទាប់ពីច្បាប់/បទប្បបញ្ញត្តិដែលត្រូវ បានបង្កើតថ្មី រឺច្បាប់/បទប្បញ្ញត្តិដែលត្រូវបានការកែប្រែថ្មីនោះត្រូវបានដាក់ឲ្យអនុវត្តក្នុងរយៈពេលជាក់លាក់ណាមួយ រឺទេ?

# Brief Explanation of RIA Application in Indonesia

1-Identify the problem

- What is the problem being addressed? How significance is it?
- Why is government action needed to correct the problem?
- Is there relevant regulation already in place?
- Why does current regulation not properly address the identified problem?
- How do the stakeholders perceive the Problem

2-Define objectives of government action

- What are the objectives, outcomes, goals or targets of government action?
- Will the government action rectify the whole problem or part of it?

3-Identify options

- What alternatives actions are available to solve the problem (to help achieve the government objectives)?
- Demonstrate that the new or revised regulations will solve the problems
- Considers alternatives *to* regulation (non-regulatory options) and alternative *forms* of regulation (regulatory options)

- Always consider the option of 'doing nothing'. Can the problem be corrected by 'private' actions of stakeholders?
- What are the risks of leaving the problem status quo? How significant are they?

<u>4-Impacts analysis</u>

- What are the costs, benefits and impacts of each different option?
- Will they result in the expected costs/benefits? What are the unintended consequences?
- Address direct and indirect impacts on environment, government, businesses, employees, consumers, and the community at large
- Address impact on sustainable development and balance societal and economic goals
- Level of analysis must be commensurate with the significant of the proposal

<u>5-Consulting Stakeholders</u>

- Who has been consulted? How was consultation conducted?
- What are their views? Is their any dissenting view?
- How did their view affect the outcome (regulation)?

- Consultation may be exercised in each stage of the regulatory process:
- To solicit stakeholders perception on the problem
- To obtain inputs on possible options
- To confirm the identified costs and benefits
- To obtain feedback on the feasibility of the options

6-Conclusion and recommended option

- What is the preferred option?
- Why this option preferred and

Others rejected?

7-Implementation and review

- How will the preferred option be implemented?
- Is the preferred option clear, consistent, comprehensible, and accessible to users?
- What means and media will be used to inform the regulatory requirements to the public (socialization)?
- How will the effectiveness of the regulation be assessed? What are the mechanisms to assure compliance?
- How will the regulation be reviewed? Is there a built-in provision to review or revoke the regulation after it has been in place for certain length of time?

## ឯកសារពិគ្រោះ

- មេរៀនបណ្ឌិត Hari Setinanto អ្នកជំនាញផ្នែកវាយតម្លៃផលប៉ះពាល់នៃច្បាប់របស់ប្រទេសឥណ្ឌូនេស៊ី
- ឯកសារសង្ខេបរបស់បណ្ឌិត កង ច័ន្ទដារារ័ត្ន នាយកប្រតិបត្តិ និងអ្នកសេដ្ឋកិច្ចនៃវិទ្យាស្ថានកម្ពុជា ដើម្បីសិក្សាការអភិវឌ្ឍ ។
- សៀវភៅវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនៃប្រទេសកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០០៩
- គេហទំព័រនៃអង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ www.oecd.org

ប្រយោគខាងក្រោម គឺជាឧទាហរណ៍ដែលបង្ហាញថា RIA ក៏ជាឧបករណ៍សិក្សា វិភាគលើច្បាប់/បទប្បញ្ញត្តិ ដ៏មានប្រជាប្រិយភាព និងមានប្រសិទ្ធភាព ដែលត្រូវបានប្រើនៅក្នុងបណ្តាប្រទេសរីកចម្រើននៅអឺរ៉ុប ៖

កាលពី ខែមករា ឆ្នាំ២០០៣ នាយករដ្ឋមន្ត្រី
នៃចក្រភពអង់គ្លេស លោក ថូនី ប្លែរ បានមាន
ប្រសាសន៍ថា៖ *មុននឹងណែនាំនូវ ច្បាប់ /*
*បទប្បញ្ញត្តិថ្មី ឬ វិធានការ ជំនួសណាមួយ គេគួរប្រើ*
*RIA ដើម្បីសិក្សា វិភាគ លើផលប៉ះពាល់ផ្នែក*
*សេដ្ឋកិច្ច សង្គម និងបរិស្ថានជាមុនសិន។*

## What the PM says:

*"Where regulations or alternative measures are introduced...decisions should be informed by a full RIA...which also includes the wider economic, social and environmental impacts"*

*Tony Blair, January 2003*

**បោះពុម្ពផ្សាយ**
**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**